ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ក្រសួងសុខាភិបាល

# ផែនទីបង្ហាញផ្លូវ

# សម្រាប់ពន្លឿនការកាត់បន្ថយអត្រា មរណភាព មាតា និងទារក

# ឆ្នាំ២០២៥ - ២០៣០

មករា ២០២៥

# បុព្វកថា

ដោយសារសន្តិភាព និងកំណើនសេដ្ឋកិច្ចស្ត្រី និងទារកទើបនឹងកើតនៅកម្ពុជា កំពុងទទួលបានសេវាសុខភាពដែលពួកគេត្រូវការ និងដែលពួកគេមានសិទ្ធិទទួលបានកាន់តែច្រើន។

ក្រសួងសុខាភិបាលបានពន្លឿនវឌ្ឍនភាព សុខភាពបន្តពូជ សុខភាពមាតា ទារក និងកុមារ តាមរយៈការអនុវត្តយុទ្ធសាស្ត្រជាតិសម្រាប់សុខភាពបន្តពូជ និងសុខភាពផ្លូវភេទ ផែនទីបង្ហាញផ្លូវសម្រាប់ពន្លឿនការកាត់បន្ថយអត្រាមរណភាពមាតា និងទារក និងផែនការយុទ្ធសាស្ត្រដទៃទៀតដែលពាក់ព័ន្ធ ដែលកិច្ចការទាំងនេះបានចូលរួមចំណែកក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិសុខាភិបាល និងការអនុវត្តកម្មវិធី សកម្មភាព នៃសន្និសីទអន្តរជាតិស្តីពីប្រជាជន និងអភិវឌ្ឍន៍ (ICPD-PoA) ដើម្បីទៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាដោយកាត់បន្ថយមរណភាពមាតាដែលអាចការពារបានត្រឹមឆ្នាំ២០៣០។

ផែនទីបង្ហាញផ្លូវសម្រាប់ពន្លឿនការកាត់បន្ថយអត្រាមរណភាពមាតា និងទារក (FTIRM) គឺជាមគ្គុទ្ទេសក៍ណែនាំដ៏មានប្រសិទ្ធភាពមួយ ដែលត្រូវបានបង្កើតឡើងចាប់តាំងពីឆ្នាំ២០១០ និងបានបន្តដោះស្រាយរបៀបវារៈដែលមិនទាន់បានបញ្ចប់នៅក្នុង FTIRM ទីពីរ ឆ្នាំ២០១៦-២០២០។ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) ឆ្នាំ២០២១-២២ បានបង្ហាញថា ប្រទេសកម្ពុជាសម្រេចបាននូវគោលដៅគួរឱ្យកត់សម្គាល់ នៃការកាត់បន្ថយអត្រាមរណភាពទារកទើបនឹងកើតមកត្រឹម ៨ នាក់ក្នុង ១ ០០០ កំណើតរស់ និងបង្កើនអត្រា នៃការសម្រាលដោយឆ្មបជំនាញរហូតដល់ ៩៩%។ អត្រាមរណភាពមាតាបានថយចុះពី ១៧០ ករណីក្នុង ១០០ ០០០ កំណើតរស់ ក្នុងឆ្នាំ២០១៤ មកត្រឹម ១៥៤ ក្នុងឆ្នាំ២០២២ ប៉ុន្តែការថយចុះនេះ នៅមិនទាន់សម្រេចគោលដៅឆ្នាំ២០២០ នៅឡើយទេ។ ដូច្នេះ នៅមានការងារជាច្រើនទៀតដែលត្រូវធ្វើ ដើម្បីឈានទៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពក្នុងការកាត់បន្ថយអត្រាមរណភាពមាតា និងរក្សានូវវឌ្ឍនភាព នៃសុខភាពទារក គឺការបន្តផ្តោតលើការបង្កើនការគ្របដណ្តប់ និងកែលម្អគុណភាព នៃការពិនិត្យផ្ទៃពោះការសម្រាលកូនដោយឆ្មបជំនាញ សេវាសង្គ្រោះបន្ទាន់ និងថែទាំទារកទើបនឹងកើត ការពិនិត្យករណីមរណភាពមាតា និងមរណភាពទារកជុំវិញកំណើត និងការឆ្លើយតប ការពន្យារកំណើត ការថែទាំព្យាបាលការមានកូនមិនតាមប្រាថ្នា (រំលូតប្រកបដោយសុវត្ថិភាព) ការលុបបំបាត់ឧបសគ្គផ្នែកហិរញ្ញវត្ថុក្នុងការទទួលបានសេវាថែទាំសុខភាព និងការកែលម្អការអនុវត្ត នៃការថែទាំសុខភាពរបស់បុគ្គល គ្រួសារ និងសហគមន៍។

ផែនទីបង្ហាញផ្លូវសម្រាប់ពន្លឿនការកាត់បន្ថយអត្រាមរណភាពមាតា និងទារកឆ្នាំ២០២៥-២០៣០ ត្រូវបានធ្វើបច្ចុប្បន្នភាពជាលើកទី៣ ដើម្បីឱ្យស្របទៅនឹងបរិបទបច្ចុប្បន្ន និងបានផ្តល់អនុសាសន៍អំពីអន្តរាគមន៍គន្លឹះដែលត្រូវអនុវត្ត ដើម្បីសម្រេចបាននូវគោលដៅកំណត់នៅឆ្នាំ២០៣០។

ថ្ងៃ[illegible]ខែ [illegible] ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី....៣០....ខែ....មេសា....ឆ្នាំ២០២៥

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**សាស្ត្រាចារ្យ ឈាង រ៉ា**

# សេចក្តីថ្លែងអំណរគុណ

ក្រសួងសុខាភិបាល សូមកោតសរសើរ និងវាយតំលៃខ្ពស់ដល់គណៈកម្មាការសម្របសម្រួលក្នុងការពង្រឹងគុណភាពថែទាំ ព្យាបាល សុខមាលភាពមាតា ទារក កុមារ និងរោគស្ត្រី ដែលមាន **លោកជំទាវសាស្ត្រាចារ្យ អ៊ឹម សិទ្ធិភារ្យ** រដ្ឋលេខាធិការក្រសួងសុខាភិបាលជាប្រធាន ក៏ដូចជាស្ថាប័នពាក់ព័ន្ធរួមមានតំណាងនាយកដ្ឋាន និងមជ្ឈមណ្ឌលជាតិនានា នៃក្រសួងសុខាភិបាល តំណាងដែលអញ្ជើញពីមន្ទីរសុខាភិបាលស្រុកប្រតិបត្តិ មន្ទីរពេទ្យ មណ្ឌលសុខភាព សាលាភូមិភាគសុខាភិបាល តំណាងគណៈកម្មាការទ្រទ្រង់មណ្ឌលសុខភាព ក្រុមទ្រទ្រង់សុខភាពភូមិ សមាគមន៍ និងគណៈវិជ្ជាជីវៈសុខាភិបាល និងអង្គការដៃគូអភិវឌ្ឍន៍សុខាភិបាល ដូចជា WHO, UNFPA, UNICEF, NCGM/JICA, USAID/FHI360, A&T, PSI, MSIC, KOFIH, RHAC, RACHA, WVI, HACC, Plan International សម្រាប់ការចូលរួមគាំទ្រនិងផ្តល់មតិយោបល់ ដែលធ្វើឱ្យផែនទីបង្ហាញផ្លូវសម្រាប់ពន្លឿនការកាត់បន្ថយអត្រាមរណភាពមាតា និងទារក ឆ្នាំ ២០២៥-២០៣០ មានលក្ខណៈគ្រប់ជ្រុងជ្រោយ។

សូមថ្លែងអំណរគុណយ៉ាងជ្រាវជ្រៅដល់អង្គការសុខភាពពិភពលោកប្រចាំនៅប្រទេសកម្ពុជា សម្រាប់ការគាំទ្របច្ចេកទេស និងថវិកាក្នុងដំណើរការអភិវឌ្ឍន៍ និងបោះពុម្ពនូវឯកសារៈដ៏មានសារសំខាន់នេះ។

# មាតិកា


បុព្វកថា..........១
សេចក្ដីថ្លែងអំណរគុណ..........២
បញ្ជីរាយឈ្មោះក្រុមការងារ គ្រប់គ្រង និងដឹកនាំប្រជុំពិភាក្សាផែនទីបង្ហាញផ្លូវសម្រាប់ពន្លឿនការកាត់បន្ថយអត្រាមរណភាពមាតា និងទារក..........៤
បញ្ជីអក្សរកាត់..........៧
សាវតា និងបរិបទ..........១០
វិធីសាស្ត្រ..........១១
វឌ្ឍនភាពមកទល់បច្ចុប្បន្ន..........១២
គោលដៅ..........១៦
សមាសធាតុ..........១៧
គោលបំណងឬសមាសធាតុទីមួយ៖ ការសម្រាលកូនដោយឆ្មបជំនាញ..........១៧
គោលបំណងឬសមាសធាតុទីពីរ៖ សេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងការថែទាំទារកទើបនឹងកើត- (EmONC) និងការពិនិត្យមរណភាពមាតា និងមរណភាពទារកជុំវិញកំណើតនិងការឆ្លើយតប (MPDSR)..........២០
គោលបំណងឬសមាសធាតុទីបី៖ ការថែទាំទារកទើបនឹងកើត..........២៣
គោលបំណងឬសមាសធាតុទីបួន៖ ការពន្យារកំណើត..........២៦
គោលបំណងឬសមាសធាតុទីប្រាំ៖ ការរំលូតកូនដោយសុវត្ថិភាព..........២៨
គោលបំណងឬសមាសធាតុទីប្រាំមួយ៖ លុបបំបាត់ឧបសគ្គផ្នែកហិរញ្ញវត្ថុក្នុងការទទួលបានសេវាថែទាំសុខភាពឆ្ពោះទៅសម្រេចបានគ្របដណ្ដប់សេវាសុខាភិបាលជាសកល (UHC)..........២៩
គោលបំណងឬសមាសធាតុទីប្រាំពីរ៖ ការចូលរួមរបស់បុគ្គល គ្រួសារ និងសហគមន៍ ដើម្បីកែលម្អសុខភាពស្ត្រី និងទារកទើបនឹងកើត..........៣០
ក្របខណ្ឌតាមដាន និងវាយតម្លៃ..........៣២
ឧបសម្ព័ន្ធទី១៖ ឯកសារយោង..........៣៧

## បញ្ជីរាយឈ្មោះក្រុមការងារ គ្រប់គ្រង និងដឹកនាំប្រជុំពិភាក្សាផែនទីបង្ហាញផ្លូវសម្រាប់ពន្លឿនការកាត់បន្ថយអត្រាមរណភាពមាតា និងទារក

| | | |
|---|---|---|
| ១-លោកជំទាវសាស្ត្រាចារ្យ | **អ៊ឹម សិទ្ធិការ្យ** | រដ្ឋលេខាធិការក្រសួងសុខាភិបាល |
| ២-លោកជំទាវសាស្ត្រាចារ្យ | **ទុន រដ្ឋាវី** | ទីប្រឹក្សាក្រសួងសុខាភិបាល |
| ៣-លោកស្រីសាស្ត្រាចារ្យជំនួយ | **គឹម រ័ត្ននា** | នាយកមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក |
| ៤- លោកស្រីវេជ្ជបណ្ឌិត | **ជាង កន្និដ្ឋា** | មន្ត្រីបច្ចេកទេស នៃអង្គការ WHO ប្រចាំនៅកម្ពុជា |
| ៥- លោកវេជ្ជបណ្ឌិត | **សុខ សុគន្ធ** | អង្គការ UNFPA ប្រចាំនៅកម្ពុជា |
| ៦-លោកវេជ្ជបណ្ឌិតឯកទេស | **លាក់ ពន្លឺ** | នាយផ្នែករងផ្នែកជំងឺទូទៅទារក និងកុមារ នៃ មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត |
| ៧-លោកស្រីវេជ្ជបណ្ឌិតឯកទេស | **គ្រាង ស៊ីដន** | អនុប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង |
| ៨-លោកវេជ្ជបណ្ឌិតឯកទេស | **រស់ សាផាត** | ប្រធានផ្នែករោគស្ត្រី និងប្រធានផ្នែកបណ្តុះបណ្តាល នៃមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក |

## គំណាងពីគណៈកម្មការសម្របសម្រួលក្នុងការពង្រឹងគុណភាពថែទាំព្យាបាលសុខមាលភាព មាតា ទារក និងកុមារ និងអង្គភាពនានានៃក្រសួងសុខាភិបាល និងអង្គការដៃគូដែលចូលរួម ពិនិត្យបញ្ចប់សេចក្តីព្រាងផែនទីបង្ហាញផ្លូវ

| | | |
|---|---|---|
| ១-ឯកឧត្តមសាស្ត្រាចារ្យ | **កុយ វ៉ាន់នី** | រដ្ឋលេខាធិការក្រសួងសុខាភិបាល |
| ២-ឯកឧត្តមសាស្ត្រាចារ្យ | **ឡឹម ដារា** | រដ្ឋលេខាធិការក្រសួងសុខាភិបាល |
| ៣-លោកជំទាវសាស្ត្រាចារ្យ | **គ្រុយ លាងស៊ីម** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល |
| ៤-លោកជំទាវសាស្ត្រាចារ្យ | **អ៊ុំ សាម៉ុល** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល |
| ៥-លោកសាស្ត្រាចារ្យ | **គី សន់ទី** | ប្រធានមន្ទីរពេទ្យគន្ធបុប្ផា |
| ៦-លោកសាស្ត្រាចារ្យ | **យ៉ៃ ចន្ទនា** | ប្រធានមន្ទីរពេទ្យជ័យវរ្ម័នទី៧ |
| ៧-លោកសាស្ត្រាចារ្យ | **គឹម អាង** | នាយករងមន្ទីរពេទ្យកុមារជាតិ |
| ៨-លោកស្រីសាស្ត្រាចារ្យ | **ខូន យ៉ាណែត** | អនុប្រធានមន្ទីរពេទ្យគន្ធបុប្ផា |
| ៩-លោកស្រីសាស្ត្រាចារ្យ | **អ៊ីង ម៉ាឡែន** | អនុប្រធានមន្ទីរពេទ្យគន្ធបុប្ផា |
| ១០-លោកស្រីវេជ្ជបណ្ឌិតឯកទេស | **ឈុន សមសោភា** | ប្រធានផ្នែកសម្ភព នៃមន្ទីរពេទ្យកាល់ម៉ែត |

| | | |
|---|---|---|
| ១១-លោកស្រីវេជ្ជបណ្ឌិតឯកទេស | **លី សុគន្ធាវី** | ប្រធានស្តីទីផ្នែកប្រពោធនកម្មទារក នៃមន្ទីរពេទ្យកាល់ម៉ែត |
| ១២-លោកវេជ្ជបណ្ឌិត | **អ៊ុយ គីណា** | នាយផ្នែកសម្ភព និងរោគស្ត្រី នៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត |
| ១៣-លោកវេជ្ជបណ្ឌិត | **ខួន ច័ន្ទតត្រា** | ប្រធានមន្ទីរពេទ្យកុមារអង្គរ |
| ១៤-លោកវេជ្ជបណ្ឌិតឯកទេស | **ម៉ី មុនីបូរិន្ទ** | អនុប្រធានមន្ទីរពេទ្យខេត្តកំពង់ចាម |
| ១៥-លោកវេជ្ជបណ្ឌិតឯកទេស | **ជា ពៅ** | ប្រធានផ្នែកជំងឺកុមារមន្ទីរពេទ្យខេត្តបាត់ដំបង |
| ១៦-លោកវេជ្ជបណ្ឌិត | **ឆេង សំអាង** | ប្រធានផ្នែកជំងឺកុមារមន្ទីរពេទ្យមិត្តភាពជប៉ុនមង្គលបូរី |
| ១៧- លោកសាស្ត្រាចារ្យ | **ឃុន លាងឃុន** | អនុប្រធានមន្ទីរពេទ្យជ័យវរ្ម័នទី៧ |
| ១៨-លោកស្រីវេជ្ជបណ្ឌិត | **ហេង រ័ត្នមុនី** | ជំនួយការប្រធានផ្នែកប្រពោធនកម្មទារក នៃមន្ទីរពេទ្យកាល់ម៉ែត |
| ១៩-លោកបណ្ឌិត | **កុយ វីរីយ៉ា** | អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ |
| ២០-កញ្ញា | **ខួន សុភាព** | ប្រធានគណៈឆ្មបកម្ពុជា |
| ២១-លោកស្រីវេជ្ជបណ្ឌិត | **ជួន កែវសំណាង** | ប្រធានផ្នែកសម្ភព និងរោគស្ត្រី នៃមន្ទីរពេទ្យព្រះអង្គឌួង |
| ២២-លោកវេជ្ជបណ្ឌិត | **គីម ពៅ** | ប្រធានផ្នែកសង្គ្រោះបន្ទាន់ទារក នៃមន្ទីរពេទ្យគន្ធបុប្ផា |
| ២៣-លោកវេជ្ជបណ្ឌិត | **សរ ប៊ុនថុង** | ប្រធានផ្នែកសង្គ្រោះទារក នៃមន្ទីរពេទ្យជ័យវរ្ម័នទី៧ |
| ២៤-លោកវេជ្ជបណ្ឌិត | **អាំង ខេមរិទ្ធ** | ប្រធានផ្នែកទារក នៃមន្ទីរពេទ្យកុមារជាតិ |
| ២៥-លោកស្រីវេជ្ជបណ្ឌិតឯកទេស | **ហេង រិទ្ធិសុបញ្ញា** | អនុប្រធានផ្នែកសម្ភព និងរោគស្ត្រី នៃមន្ទីរពេទ្យព្រះអង្គឌួង |
| ២៦-លោកស្រីវេជ្ជបណ្ឌិតឯកទេស | **សៀក ម៉េង** | នាយផ្នែកជំងឺទូទៅទារក និងកុមារ នៃមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត |
| ២៧-លោកស្រីវេជ្ជបណ្ឌិត | **នៅ លក្ខិណា** | នាយផ្នែកអគារទារក នៃមន្ទីរពេទ្យកុមារអង្គរ |
| ២៨-លោកវេជ្ជបណ្ឌិត | **លន ទ្រីយ៍ប៉ាទ្រីច** | អនុប្រធានមន្ទីរពេទ្យខេត្តកំពង់ចាម |
| ២៩លោកស្រី | **ឆាយ ស្វែងជាអាធី** | ប្រធានសមាគមឆ្មបកម្ពុជា |
| ៣០-លោកវេជ្ជបណ្ឌិត | **លី វិជ្ជារ៉ាវុធ** | ប្រធាននាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល |
| ៣១-លោកវេជ្ជវេជ្ជបណ្ឌិតឯកទេស | **ង៉ែត វិត្ថូ** | ប្រធានផ្នែកសម្ភព និងរោគស្ត្រី នៃមន្ទីរពេទ្យខេត្តបាត់ដំបង |
| ៣២-លោកស្រីវេជ្ជបណ្ឌិត | **សៀង លំអងគន្ធា** | ប្រធានកម្មវិធីជាតិសុខភាពបន្តពូជនៃមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក |

| | | |
|---|---|---|
| ៣៣-លោកវេជ្ជបណ្ឌិត | **យ៉ោម សុផល** | ប្រធានផ្នែកសម្ភព នៃមន្ទីរពេទ្យជ័យវរ្ម័នទី៧ |
| ៣៤-លោកវេជ្ជបណ្ឌិតឯកទេស | **សោ សុខុម** | ប្រធានផ្នែករោគស្ត្រី នៃមន្ទីរពេទ្យបង្អែកខេត្តតាកែវ |
| ៣៥-លោកសាស្ត្រាចារ្យ | **គាន់ អូន** | ប្រធានផ្នែករោគស្ត្រី នៃមន្ទីរពេទ្យកាល់ម៉ែត |
| ៣៦-លោកវេជ្ជបណ្ឌិត | **អ៊ុក វិជ្ជា** | ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ |
| ៣៧-លោកវេជ្ជបណ្ឌិតឯកទេស | **ម៉ិន ស័ក្តិសិដ្ឋ** | មន្ត្រីផ្នែកប្រពោធនកម្មទារក នៃមន្ទីរពេទ្យកាល់ម៉ែត |
| ៣៨-លោកស្រី | **ហេង ឌីម** | មន្ត្រីកម្មវិធីជាតិសុខភាពបន្តពូជ នៃមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក |
| ៣៩-លោកវេជ្ជបណ្ឌិត | **តែ វ៉ាន់ថា** | ប្រធានមន្ទីរពេទ្យខេត្តតាកែវ |
| ៤០-លោកវេជ្ជបណ្ឌិតឯកទេស | **អាត់ បាលី** | មន្ត្រីផ្នែកប្រពោធនកម្មទារក នៃមន្ទីរពេទ្យកាល់ម៉ែត |
| ៤១-លោក | **ខួន ប្រុស** | មន្ត្រីកម្មវិធី UNFPA |

# បញ្ជីអក្សរកាត់

| | |
|---|---|
| **ANC** | ការថែទាំផ្ទៃពោះមុនពេលសម្រាល |
| **ADM** | បរិញ្ញាបត្ររងឆ្មប |
| **AYFSRH** | សុខភាពផ្លូវភេទ និងសុខភាពបន្តពូជរបស់យុវវ័យប្រកបដោយមិត្តភាព |
| **A&T** | អង្គការ Alive and Thrive |
| **BCC** | ការប្រាស្រ័យទាក់ទងដែលនាំឱ្យមានការផ្លាស់ប្តូរឥរិយាបថ |
| **BDNM** | បរិញ្ញាបត្រគិលានុបដ្ឋាក-យិកា និងឆ្មប |
| **BF** | ការបំបៅកូនដោយទឹកដោះម្តាយ |
| **BSM** | បរិញ្ញាបត្រវិទ្យាសាស្ត្រផ្នែកឆ្មប |
| **BEmONC** | ការសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងថែទាំទារកទើបនឹងកើតកម្រិតមូលដ្ឋាន |
| **CAC** | ការថែទាំការរំលូតកូនប្រកបដោយសុវត្ថិភាព |
| **CDHS** | ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា |
| **CEmONC** | ការសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងថែទាំទារកទើបនឹងកើតគ្រប់ជ្រុងជ្រោយ |
| **CIP** | ផែនការវិនិយោគឃុំ |
| **CNP** | គម្រោងអាហារូបត្ថម្ភកម្ពុជា |
| **CPA** | សំណុំសកម្មភាពបង្គ្រប់ |
| **CPAP** | ម៉ាស៊ីនសម្រាប់ដាក់ជួយផ្លូវដង្ហើម |
| **CSDG** | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា |
| **D&D** | វិមជ្ឈការ និងវិសហមជ្ឈការ |
| **EENC** | ការថែទាំជាសារវ័ន្តសម្រាប់ទារកទើបនឹងកើត |
| **EENC-HCT** | ក្រុមការងារស្នូលសម្រាប់ការថែទាំជាសារវ័ន្តសម្រាប់ទារកទើបនឹងកើតនៅមន្ទីរពេទ្យ |
| **EmONC** | សេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងថែទាំទារកទើបនឹងកើត |
| **EPMM** | ការបញ្ចប់អត្រាមរណភាពមាតាដែលអាចទប់ស្កាត់បានត្រឹមឆ្នាំ២០៣០ |
| **EPNDS** | ការបញ្ចប់មរណភាពទារក និងទារកកើតស្លាប់ ដែលអាចទប់ស្កាត់បានត្រឹមឆ្នាំ២០៣០ |
| **EW** | អ្នកបម្រើសេវាកម្សាន្ត |
| **FP** | ផែនការគ្រួសារ ឬ ការពន្យារកំណើត |
| **FHI** | អង្គការ Family Health International |

| | |
|---|---|
| **FTIRM** | ផែនទីបង្ហាញផ្លូវសម្រាប់ពន្លឿនការកាត់បន្ថយអត្រាមរណភាព |
| **HACC** | គណៈកម្មាការសម្របសម្រួលប្រយុទ្ធនឹងជំងឺអេដស៍ ឬ បណ្ដាញអង្គការមិនមែនរដ្ឋាភិបាល |
| **HCMC** | គណៈកម្មាការគ្រប់គ្រងមណ្ឌលសុខភាព |
| **HEF** | មូលនិធិសមធម៌សុខាភិបាល |
| **HEQIP** | គម្រោងលើកកម្ពស់គុណភាព និងសមធម៌សុខាភិបាល |
| **INC** | ការថែទាំទារកទើបនឹងកើត |
| **KMC** | ការថែទាំទារកតាមរបៀបម្ដាយកង់ហ្គូរូ |
| **LGTBQI** | ស្ត្រីស្រលាញ់ស្ត្រី បុរសស្រលាញ់បុរស អ្នកប្ដូរយេនឌ័រ អ្នកស្រលាញ់ពីរភេទ អ្នកមិនកំណត់អត្តសញ្ញាណយេនឌ័រខ្លួនឯង និងអន្តរភេទ |
| **MA** | ការរំលូតកូនដោយឱសថ |
| **MCH** | សុខភាពមាតា និងទារក |
| **MDA** | ការស្រាវជ្រាវមរណភាពមាតា |
| **MDG** | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ |
| **MDSR** | ការស្រាវជ្រាវមរណភាពមាតា និងការឆ្លើយតប |
| **MgSO4** | ម៉ាញ៉េស្យូមស៊ុលហ្វាត |
| **MSIC** | អង្គការម៉ារីស្តូបអន្តរជាតិកម្ពុជា |
| **MMR** | អត្រាមរណភាពមាតា |
| **MNH** | សុខភាពមាតា និងទារកទើបនឹងកើត |
| **NMR** | អត្រាមរណភាពទារកទើបនឹងកើត |
| **NSDP** | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| **NSSF** | បេឡាជាតិរបបសន្តិសុខសង្គម |
| **NSSRHR** | យុទ្ធសាស្ត្រជាតិសម្រាប់សុខភាពផ្លូវភេទ សុខភាពបន្តពូជ និងសិទ្ធិ |
| **OOP** | ចំណាយប្រាក់ពីហោប៉ៅ |
| **PAC** | ការថែទាំក្រោយរំលូតកូន |
| **PHC** | ការថែទាំសុខភាពបឋម |
| **PHC BIF** | ក្របខណ្ឌអនុវត្តការជំរុញបង្កើនការងារថែទាំសុខភាពបឋម |

| | |
|---|---|
| **PNC** | ការថែទាំក្រោយសម្រាល |
| **PSI** | អង្គការអន្តរជាតិបម្រើសុខភាពប្រជាជន |
| **PSL** | ភាពជាដៃគូរដើម្បីសង្គ្រោះជីវិត |
| **RACHA** | សម្ព័ន្ធសុខភាពកុមារ និងសុខភាពបន្តពូជ |
| **RHAC** | អង្គការថែទាំសុខភាពគ្រួសារកម្ពុជា |
| **RMNH** | សុខភាពបន្តពូជ សុខភាពមាតា និងទារក |
| **SBA** | ការសម្រាលកូនដោយឆ្មបជំនាញ |
| **UNFPA** | មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន |
| **UNICEF** | មូលនិធិសហប្រជាជាតិដើម្បីកុមារ |
| **USAID** | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ |
| **VCAT** | ការបញ្ជាក់អំពីគុណតម្លៃ និងការផ្លាស់ប្តូរអាកប្បកិរិយា |
| **VHSG** | ក្រុមទ្រទ្រង់សុខភាពភូមិ |
| **WHO** | អង្គការសុខភាពពិភពលោក |
| **WVI** | អង្គការទស្សនៈពិភពលោកអន្តរជាតិ |

# សាវតា និងបរិបទ

នៅទូទាំងពិភពលោក ក្នុងឆ្នាំ២០២០ មានស្ត្រីម្នាក់បានស្លាប់រៀងរាល់ពីរនាទីម្តង ដោយ ៩៥% នៃការស្លាប់នោះកើតឡើងនៅក្នុងប្រទេសដែលមានប្រាក់ចំណូលទាប និងមធ្យម[1] ។

ការវិនិយោគលើសុខភាពបន្តពូជ សុខភាពមាតា ទារកទើបនឹងកើត និងមនុស្សវ័យជំទង់ ទទួលបានភាគលាភយ៉ាងច្រើន មិនត្រឹមតែចំពោះសុខភាពប្រជាជនប៉ុណ្ណោះទេ ប៉ុន្តែក៏ចំពោះធនធាន ឬមូលធនមនុស្សរបស់ប្រទេសមួយផងដែរ ដែលជាកត្តាជំរុញដ៏សំខាន់ ទាំងកំណើនសេដ្ឋកិច្ច និងសង្គម។ គេបានប៉ាន់ស្មានថា រៀងរាល់ប្រាក់មួយដុល្លារ ដែលបានវិនិយោគនៅអាស៊ី និងអាចទទួលបានអត្ថប្រយោជន៍ត្រឡប់មកវិញប្រហែលប្រាំបួនដុល្លារ ក្នុងឆ្នាំ២០៥០។[2]

ប្រទេសកម្ពុជាសម្រេចបានសមិទ្ធិផលសំខាន់ៗក្នុងការពង្រឹងសុខភាពមាតា និងទារកនៅក្នុងទសវត្សរ៍កន្លងមក។ អត្រាមរណភាពរបស់កុមារអាយុក្រោមប្រាំឆ្នាំ និងទារកទើបនឹងកើត ត្រូវបានកាត់បន្ថយជាងពាក់កណ្តាល រវាងឆ្នាំ២០១៤ និង ឆ្នាំ២០២១/២២ ពោលគឺពី ៣៥ មកត្រឹម ១៦ ករណី និងពី ១៨ មកត្រឹម ៨ ករណីក្នុង ១ ០០០ កំណើតរស់រៀងគ្នា។[3] បើប្រៀបធៀបនឹងមធ្យមភាគជាសកលដែលមានការថយចុះ ១៥% ហើយជាញឹកញាប់ការថយចុះ នៃអត្រាមរណភាពទារកទើបនឹងកើតគឺពិបាកនឹងធ្វើអោយមានការប្រែប្រួលដូច្នេះនេះជាសមិទ្ធិផលដ៏ធំមួយ។ ស្ត្រីស្ទើរតែគ្រប់រូប សម្រាលកូនដោយអ្នកផ្តល់សេវាដែលមានជំនាញ ហើយភាគច្រើន នៃការសម្រាលគឺនៅក្នុងមូលដ្ឋានសុខាភិបាល។ នៅពេលនេះ វាមានសារសំខាន់ក្នុងការថែរក្សា និងពង្រឹងបន្ថែមលើសមិទ្ធិផលដែលទទួលបានកន្លងមក រួមទាំងការដោះស្រាយវិសមភាពដែលនៅសេសសល់ផងដែរ ដើម្បីធានាថាពុំមាននរណាម្នាក់ត្រូវបានទុកចោលនោះទេ។

ជាមួយគ្នានេះ នៅខណៈពេលដែលអត្រាមរណភាពមាតាបានថយចុះ ពីការប៉ាន់ស្មាន ១៧០ ទៅ ១៥៤ ករណីក្នុង ១០០ ០០០ កំណើតរស់ នៅចន្លោះឆ្នាំ២០១៤ និង ឆ្នាំ២០២១/២២ ការថយចុះនេះយឺតជាងគោលដៅដែលបានកំណត់ និងចាំបាច់ត្រូវបង្កើនល្បឿនឱ្យបានខ្លាំង ដើម្បីឈានទៅសម្រេចបានគោលដៅ **CSDGs** ដែលមានចំនួន ៧០ ករណី ត្រឹមឆ្នាំ២០៣០។

---

[1]និន្នាការ នៃអត្រាមរណភាពមាតា ចាប់ពីឆ្នាំ២០០០ ដល់ ឆ្នាំ២០២០៖ ប៉ាន់ស្មានដោយ **WHO UNICEF UNFPA** ក្រុមធនាគារពិភពលោក និង **UNDESA**/ផ្នែកប្រជាជន។ ទីក្រុងហ្សឺណែវ៖ អង្គការសុខភាពពិភពលោក ឆ្នាំ២០២៣។ អាជ្ញាប័ណ្ណ៖ **CC BY-NC-SA 3.0 IGO.**

[2]**Stenberg K, Axelson H, Sheehan P, Anderson I, Gülmezoglu A M.** និងអ្នកដទៃទៀត. ឆ្នាំ២០១៤. "ជំរុញការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចតាមរយៈការវិនិយោគលើសុខភាពស្ត្រី និងកុមារ៖ ក្របខណ្ឌវិនិយោគជាសកលថ្មី." **The Lancet 383 (9925): 1333–54.**
**doi: 10.1016 /S0140-6736(13)62231-X**

[3]ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០១៤ និង ២០២១/២២។

ផែនទីបង្ហាញផ្លូវសម្រាប់ពន្លឿនការកាត់បន្ថយអត្រាមរណភាពមាតា និងទារក (FTIRM) ឆ្នាំ២០១០-២០១៥ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៩ ជាមធ្យោបាយពន្លឿនការកាត់បន្ថយអត្រាមរណភាពមាតា និងទារក និងមានវឌ្ឍនភាពឆ្ពោះទៅរកការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDG) ទី៤ និង ទី៥។ FTIRM ទីពីរ បានបន្តពី FTIRM ទីមួយ និងបានគូសបញ្ជាក់អំពីអាទិភាពសម្រាប់ការកាត់បន្ថយអត្រាមរណភាពមាតា និងទារក នៅចន្លោះឆ្នាំ២០១៦ ដល់ឆ្នាំ២០២០។ FTIRM ឆ្នាំ២០២៥-២០៣០ គឺបន្តពី FTIRM ទីពីរ ដោយគូសបញ្ជាក់អំពីរបៀបវារៈដែលមិនទាន់បានដោះស្រាយរួច និងផ្អែកលើអាទិភាព យុទ្ធសាស្ត្រ និងគោលនយោបាយជាតិ ដើម្បីបង្កើនប្រសិទ្ធភាពសេវា RMNH ពន្លឿនការកាត់បន្ថយអត្រាមរណភាពមាតា ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ទី៣ និងបន្តកាត់បន្ថយការស្លាប់របស់ទារកទើបនឹងកើតត្រឹមឆ្នាំ២០៣០។

FTIRM ឆ្នាំ២០២៥-២០៣០ គឺជាឯកសាររបស់ក្រសួងសុខាភិបាល ដែលត្រូវបានបង្កើតឡើងស្របតាមយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល (យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី ១) យុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា (CSDG) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) ឆ្នាំ២០១៩-២០២៣ ផែនការយុទ្ធសាស្ត្រសុខាភិបាលឆ្នាំ២០២៤-២០៣០ គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ (D&D) ក្របខណ្ឌអនុវត្តការជំរុញបង្កើនការងារថែទាំសុខភាពបឋម (PHC BIF) យុទ្ធសាស្ត្រ និងផែនការអនុវិស័យ ដូចជាយុទ្ធសាស្ត្រជាតិសម្រាប់សុខភាពផ្លូវភេទ សុខភាពបន្តពូជ និងសិទ្ធិ (NSSRHR) ឆ្នាំ២០១៧-២០២៣ ផែនការកែលម្អការសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងថែទាំទារកទើបនឹងកើត (EmONC) ឆ្នាំ២០២១-២០២៥ និងផែនការសកម្មភាពរយៈពេលប្រាំឆ្នាំសម្រាប់ការថែទាំទារកទើបនឹងកើតដែលត្រូវបានបន្ថែមរយៈពេលអនុវត្ត ។

## វិធីសាស្ត្រ

FTIRM ឆ្នាំ២០២៥-២០៣០ ត្រូវបានបង្កើតឡើងតាមរយៈដំណើរការពិគ្រោះយោបល់ ដែលរួមមានបទសម្ភាសន៍នានា ព្រមទាំងកិច្ចប្រជុំពិគ្រោះយោបល់ចំនួនពីរលើក ដែលបានរៀបចំឡើងក្នុងខែមេសា ឆ្នាំ២០២៣ ដែលមានការចូលរួមពីតំណាងរាជរដ្ឋាភិបាលកម្ពុជា ជាពិសេស ក្រសួងសុខាភិបាល មូលដ្ឋានសុខាភិបាល និងតំណាងវិជ្ជាជីវៈ ដៃគូអភិវឌ្ឍន៍ និង NGOs សំខាន់ៗ ដែលបម្រើការងារនៅក្នុងវិស័យសុខភាពមាតា និងទារក។

FTIRM ថ្មីនេះ (ឆ្នាំ២០២៥-២០៣០) ត្រូវបានរៀបចំឡើងផ្អែកលើ ការត្រួតពិនិត្យឡើងវិញលើ FTIRM ឆ្នាំ២០១៦-២០២០ ការត្រួតពិនិត្យឡើងវិញលើផែនការកែលម្អ EmONC ឆ្នាំ២០១៦-២០២០ ការត្រួតពិនិត្យឡើងវិញលើការស្រាវជ្រាវមរណភាពមាតា និងការឆ្លើយតប (MDSR) ឆ្នាំ២០១៩ របាយការណ៍វឌ្ឍនភាព EENC រៀងរាល់ពីរឆ្នាំម្តង និងការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (CDHS) ឆ្នាំ២០២១-២២។

## វឌ្ឍនភាពមកទល់បច្ចុប្បន្ន

វឌ្ឍនភាពត្រូវបានបង្ហាញតាមរយៈភាពល្អប្រសើរឡើង នៃសុខភាពមាតា និងទារក នៅចន្លោះឆ្នាំ២០១៦ ដល់ឆ្នាំ២០២២។ ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជាបានប៉ាន់ស្មានអត្រាមរណភាពមាតាបានថយចុះមក ត្រឹម ១៥៤ ក្នុង ១០០ ០០០ កំណើតរស់ និងអត្រាមរណៈទារកត្រឹម ៨ ក្នុង ១ ០០០ កំណើតរស់ ដែលការ ថយចុះ នៃមរណភាពទារកសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពមុនកាលកំណត់។ សូចនាករចំនួនម្ភៃបួន (២៤) នៅក្នុង FTIRM ឆ្នាំ២០១៦-២០២០ ត្រូវបានពិនិត្យ និងបានរកឃើញថា សូចនាករចំនួន ៥ សម្រេចបានយ៉ាង ពេញលេញ (ពណ៌បៃតង) សូចនាករចំនួន ៩ សម្រេចបានខ្លះ (ពណ៌លឿង) សូចនាករចំនួន ៧ មិនសម្រេចបាន នោះទេ (ពណ៌ក្រហម) និងសូចនាករចំនួន ៣ មិនអាចវាយតម្លៃបាន ដោយសារពុំមានទិន្នន័យ ឬមិនបានកំណត់ គោលដៅសម្រាប់សូចនាករទាំងនេះ។ សេចក្តីសង្ខេបអំពីលទ្ធផលពី FTIRM ឆ្នាំ២០១៦-២០២០ មាននៅ ក្នុងតារាងខាងក្រោម។ ព័ត៌មានលម្អិតបន្ថែមទៀតមាននៅក្នុងរបាយការណ៍ត្រួតពិនិត្យឡើងវិញលើ FTIRM ឆ្នាំ២០១៦-២០២០។

| គោលដៅ/គោលបំណង | សូចនាករ | ទិន្នន័យមូលដ្ឋាន ឆ្នាំ២០១៤ | គោលដៅ ឆ្នាំ២០២០ | វឌ្ឍនភាព ឆ្នាំ២០២២ |
|---|---|---|---|---|
| កាត់បន្ថយអត្រាមរណភាពមាតាមកត្រឹម ១៤០ ក្នុង ១០០ ០០០ កំណើតរស់ និងកាត់បន្ថយអត្រាមរណភាពទារកមកត្រឹម ១៤ ករណីក្នុង ១ ០០០ ត្រឹម ២០២០ | MMR | ១៧០ | ១៤១[4] | ១៥៤[5] |
| | NMR | ១៨ | ១៤ | ៨ |
| បង្កើនគុណភាព និងការគ្របដណ្តប់លើការពិនិត្យផ្ទៃពោះមុនសម្រាលដោយឆ្មបជំនាញ និងការថែទាំក្រោយសម្រាល (ជារួម និងជាពិសេសក្នុងចំណោមក្រុមប្រជាជន | % នៃមណ្ឌលសុខភាពដែលមានឆ្មបមធ្យមយ៉ាងតិច ២ រូប | ៤១% (៤៥២/១១០៥) | ៥០% | ៨៣% (១០៥២/១២៦៨) |
| | % នៃស្ត្រីដែលទទួលបានការពិនិត្យផ្ទៃពោះមុនសម្រាលយ៉ាងតិច៤ដង | ៧៦% | ៩០% | ៨៦,៣% (ជារួម)<br>៧៤,២% (ក្រុមប្រជាជនដែលមានប្រាក់ចំណូលទាបបំផុត)<br>៧១,១% (គ្មានការអប់រំ) |

[4] CSDGs ឆ្នាំ២០១៦-២០៣០. បញ្ជីគោលដៅដែលបានកែសម្រួល និងសូចនាករតាមគោលដៅ ខែកក្កដា ឆ្នាំ២០២២. MoP.

[5] CDHS ឆ្នាំ២០២១-២២

| | | | | |
|---|---|---|---|---|
| ដែលមានប្រាក់ចំណូល និងការអប់រំទាបបំផុត) | % នៃការសម្រាលកូននៅក្នុងមូលដ្ឋានសុខាភិបាល (ជារួម និងត្រូវបានបែងចែកតាមកម្រិតនៃប្រាក់ចំណូល និងការអប់រំ) | ៨៣% (ជារួម) ៦៨% (ក្រុមដែលមានប្រាក់ចំណូលទាបបំផុត) ៦៨% (គ្មានការអប់រំ) | ៩០% (ជារួម) ៨០% (ក្រុមដែលមានប្រាក់ចំណូលទាបបំផុត) ៨០% (គ្មានការអប់រំ) | ៩៨% (ជារួម) ៩៣,៥% (ក្រុមដែលមានប្រាក់ចំណូលទាបបំផុត) ៩១,៨% (គ្មានការអប់រំ) |
| | % នៃស្ត្រីដែលទទួលបាន PNC ភ្លាមៗ (ក្នុងរយៈពេលពីរថ្ងៃក្រោយពេលសម្រាល) | ៩០% | ៩៥% | ៨៤,៥% (ជារួម) ៧៦% (ក្រុមដែលមានប្រាក់ចំណូលទាបបំផុត) ៧៧,២% (គ្មានការអប់រំ) |
| ពង្រឹងការគ្របដណ្តប់សេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងថែទាំទារកទើបនឹងកើត ដូច្នេះមានមូលដ្ឋាន EmONC យ៉ាងតិច ៥ (CEmONC + BEmONC) ក្នុងចំណោមប្រជាជន ៥០០ ០០០ នាក់ រួម ទាំងមូលដ្ឋាន CEmONC យ៉ាងតិចមួយ | មានមូលដ្ឋាន EmONC សម្រាប់ប្រជាជន ៥០០ ០០០ នាក់ | ២,៣៥ (ដំណើរការ) ៤,៨៥ (បានដំឡើងកម្រិត) | យ៉ាងតិច ៥ (មូលដ្ឋាន EmONC ≥ ១៦០) | ២,៦២ (ដំណើរការ) ៥,៧៦ (បានដំឡើងកំរិត) |
| | មានមូលដ្ឋាន BEmONC សម្រាប់ប្រជាជន ៥០០ ០០០ នាក់ | ១,០៤ (ដំណើរការ) ៣,៦២ (បានដំឡើងកម្រិត) | យ៉ាងតិច ៤ (មូលដ្ឋាន BEmONC ≥ ១២៥) | ១,៤៨ (ដំណើរការ) ៤,៤១ (បានដំឡើងកំរិត) |
| | មានមូលដ្ឋាន CEmONC សម្រាប់ប្រជាជន ៥០០ ០០០ នាក់ | ១,៣១ (ដំណើរការ) ១,២២ (បានដំឡើងកម្រិត) | យ៉ាងតិច ១ (មូលដ្ឋាន CEmONC ≥ ៣៥) | ១,១៤ (ដំណើរការ) ១,៣៥ (បានដំឡើងកំរិត) |
| | % នៃការសម្រាលកូនដោយវះកាត់ | ជារួម៖ ៦,៣% កំពង់ស្ពឺ៖ ២,២% ពោធិ៍សាត់៖ ២,២% ព្រះវិហារ៖ ២,៣% ស្ទឹងត្រែង៖ ២,៣% ភ្នំពេញ៖ ១៤,៤% | ជារួម៖ ១០% ថ្នាក់ក្រោមជាតិ៖ ពុំមានខេត្តដែលទាបជាង ៣,៥% នោះទេ ហើយភ្នំពេញមិនលើសពី ១៧% | ជារួម៖ ១៧,៩% កំពង់ស្ពឺ៖ ១៦,២% ពោធិ៍សាត់៖ ១៥,៩% វិហារ៖ ៨,៦% ស្ទឹងត្រែង៖ ៩,៣% រតនគិរី៖ ២,០% |

| | | | | |
|---|---|---|---|---|
| | | | | ភ្នំពេញ៖ ២៩,១% |
| ពង្រឹងគុណភាព និង ការគ្របដណ្តប់ នៃការថែទាំទារកទើបនឹងកើត | % នៃឆ្មបជំនាញទទួលបានការបណ្តុះបណ្តាលផ្នែកថែទាំជាសារវ័ន្ត/ការថែទាំទារកទើបនឹងកើតភ្លាម | ៧១%[6] បុគ្គលិកមន្ទីរពេទ្យបានទទួលការបង្វឹក EENC (៣៨០៣/៥៣៤៧) | ៨០% | ៧៦%[7] បុគ្គលិកមន្ទីរពេទ្យបានទទួលការបង្វឹក EENC (៤២១៦/៥៥៧៨) |
| | % នៃមូលដ្ឋានសុខាភិបាលចំនុចដែលបានអនុវត្តកញ្ចប់ការថែទាំទារក (Expanded INC) | ៩០%[8] (១១៣៩/ ១២៧២) | ៩០% | ៨៩%[9] (១១៨៧/១៣២៨) |
| | % នៃទារកទើបនឹងកើតបានទទួលការថែទាំក្រោយសម្រាលភ្លាម (ក្នុងរយៈពេល ២ថ្ងៃក្រោយពេលសម្រាល) | ៧៦,៥% | ៩៥% | ៧៧,៨% |
| | % នៃទារកដែលត្រូវបានបំបៅដោយទឹកដោះម្តាយ ក្នុងរយៈពេល ១ ម៉ោងក្រោយពេលកើត | ៦៣% | ៧៦% | ៥៣,៨% |
| បង្កើនការប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើប និងបង្កើនសមាមាត្រ | % នៃស្ត្រី ដែលត្រូវការពន្យារកំណើតមានការពេញចិត្ត | ៨២,៧% | ៨៥% | ៨៤,០% |

[6] របាយការណ៍វឌ្ឍនភាព EENC រៀងរាល់ពីរឆ្នាំម្តង លើកទីពីរ ឆ្នាំ២០១៦-២០១៧. WHO តំបន់ប៉ាស៊ីហ្វិកខាងលិច

[7] របាយការណ៍វឌ្ឍនភាព EENC រៀងរាល់ពីរឆ្នាំម្តង លើកទីបី ឆ្នាំ២០១៨-២០២០. WHO តំបន់ប៉ាស៊ីហ្វិកខាងលិច

[8] របាយការណ៍វឌ្ឍនភាព EENC រៀងរាល់ពីរឆ្នាំម្តង លើកទីពីរ ឆ្នាំ២០១៦-២០១៧. WHO តំបន់ប៉ាស៊ីហ្វិកខាងលិច

[9] របាយការណ៍វឌ្ឍនភាព EENC រៀងរាល់ពីរឆ្នាំម្តង លើកទីបី ឆ្នាំ២០១៨-២០២២. WHO តំបន់ប៉ាស៊ីហ្វិកខាងលិច

| | | | | |
|---|---|---|---|---|
| នៃតម្រូវការពន្យារកំណើតមានការពេញចិត្ត | % នៃស្ត្រី ដែលត្រូវការពន្យារកំណើតមានការពេញចិត្តចំពោះមធ្យោបាយពន្យារកំណើតទំនើប | ៥៧,៤% | ៦២% | ៦០,៦% |
| | អត្រាប្រេវ៉ាឡង់នៃការពន្យារកំណើតតាមបែបទំនើប | ៣៩% | ៤៨% | ៤៥% |
| បង្កើនចំនួន មូលដ្ឋានសុខាភិបាលដែលផ្តល់សេវារំលូតកូនដោយសុវត្ថិភាព និងកាត់បន្ថយ សមាមាត្រស្ត្រីដែលរំលូតកូនជាច្រើនដងនិងរំលូតកូនដោយគ្មានសុវត្ថិភាព | # នៃមូលដ្ឋានសុខាភិបាលដែលផ្តល់សេវារំលូតកូនដោយសុវត្ថិភាព | ៦០៤ | ៨៨០ | ៧៩៣[10] |
| | % នៃស្ត្រីដែលរាយការណ៍ថាបានរំលូតកូនជាច្រើនដង | ៣,៦% | ២,០% | គ្មាន |
| | % នៃស្ត្រីដែលបានរំលូតកូនតែមិនបានទទួលការរំលូតដោយបុគ្គលិកជំនាញនៅពេលរំលូតកូនលើកចុងក្រោយ | ៤០% | ៣០% | គ្មាន |
| ធានាថាស្ត្រីក្នុងវ័យបន្តពូជទាំងអស់អាចទទួលបានកញ្ចប់សេវាសុខភាពបន្តពូជសេវាសុខភាពមាតា និងទារកសារវ័ន្តនៅពេលត្រូវការដោយពុំមានបញ្ហាហិរញ្ញវត្ថុ | % នៃស្ត្រីក្នុងវ័យបន្តពូជ ដែលគ្របដណ្តប់ដោយការគាំពារសុខភាពសង្គម (រួមទាំង HEF និងការធានា | TBD | TBD | ២២,៨% នៃស្ត្រីដែលរំពឹងទុកថា មានផ្ទៃពោះ[11] បានចុះឈ្មោះនៅក្នុងគ្រួសារមានប័ណ្ណក្រីក្រ និង បសស បានសម្រាលកូននៅ មូលដ្ឋានសុខាភិបាល និងត្រូវបានទូទាត់ដោយ HEF និង |

[10] NMCHC, MoH

[11] ស្ត្រីដែលបានរំពឹងទុកថាមានផ្ទៃពោះនៅឆ្នាំ ២០២២ តាមការប៉ាន់ស្មាន មានចំនួន ៣៥៩.៤១២ នាក់។

| | | | | |
|---|---|---|---|---|
| | រ៉ាប់រងសុខភាពជាតិ និងរបបដទៃទៀត) % នៃការសម្រាលកូន ដែលត្រូវបានគ្របដណ្តប់ដោយការគាំពារសង្គម | | | NSSF។ ៦,៧% នៃស្ត្រីដែលរៀបអាពាហ៍ពិពាហ៍រួចស្ថិតក្នុងវ័យបន្តពូជ[12]។ |
| កែលម្អការអនុវត្តក្នុងការថែទាំបុគ្គល គ្រួសារ និងសហគមន៍ និងការស្វែងរកការថែទាំសម្រាប់ស្ត្រី និងទារកទើបនឹងកើត | អត្រាសម្រាលកូនក្នុងចំណោមយុវវ័យ (១៥-១៩) | ៥៧ | ៥១ | ៤៨ |
| | % ស្ត្រីរៀបការកំពុងប្រើប្រាស់មធ្យោបាយពន្យារកំណើតបុរាណ | ១៧,៥% | ១២% | ១៧,២% |
| | % នៃស្ត្រីដែលដឹងថាការរំលូតកូនគឺស្របច្បាប់ | ១២% (នៅក្នុងខេត្តទាំង ៨ ដែលបានទទួលជំនួយពី PSL) | ៣០% | ១៤,៦% (នៅក្នុងខេត្តទាំង ៨ ដែលបានទទួលជំនួយពី PSL) |

បញ្ហាប្រឈមនៅមាននៅគ្រប់សមាសធាតុនៃ **FTIRM** ដូច្នេះនៅមានរបៀបវារៈដែលមិនទាន់សម្រេចបាន និងដែលត្រូវបំពេញត្រឹមឆ្នាំ ២០៣០ ជាពិសេសការថែទាំមុនពេលសម្រាល ក្នុងអំឡុងពេលសម្រាល និងក្រោយពេលសម្រាល សេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងការថែទាំទារក ការពន្យារកំណើត ការរំលូតកូនដោយសុវត្ថិភាព និងការសម្រេចបាននូវការគ្របដណ្តប់ នៃសេវាសុខភាពជាសកល។

## គោលដៅ

គោលដៅរបស់ផែនទីបង្ហាញផ្លូវសម្រាប់ពន្លឿនការកាត់បន្ថយអត្រាមរណភាពមាតា និងទារក ឆ្នាំ២០២៥-២០៣០ គឺកាត់បន្ថយអត្រាមរណភាពមាតាមកត្រឹម ៧០[13] ក្នុង ១០០ ០០០ កំណើតរស់ និងកាត់បន្ថយការស្លាប់របស់ទារកទើបនឹងកើតបន្ថែមទៀតឲ្យបានតិចជាង ៨ ក្នុង ១ ០០០ កំណើតរស់ ត្រឹមឆ្នាំ២០៣០។

[12] ស្ត្រីដែលរៀបអាពាហ៍ពិពាហ៍រួច ដែលស្ថិតក្នុងវ័យបន្តពូជ នៅឆ្នាំ ២០២២ តាមការប៉ាន់ស្មាន មានចំនួន ៣,១៨៥,៧៧២ នាក់។
[13] **CSDG** ឆ្នាំ២០១៦-២០៣០. បញ្ជីគោលដៅដែលត្រូវបានកែសម្រួល និងសូចនាករតាមគោលដៅ ខែកក្កដា ឆ្នាំ២០២២. **MoP**

## សមាសធាតុ

FTIRM ឆ្នាំ២០២៥-២០៣០ មានគោលបំណងឬសមាសធាតុស្នូលចំនួនប្រាំ និងសមាសធាតុគាំទ្រចំនួនពីរ។ សមាសធាតុស្នូលនៃ FTIRM ឆ្នាំ២០១៦-២០២០ ទាំងអស់ នឹងត្រូវបន្តធ្វើអន្តរាគមន៍សំខាន់ៗថ្មីៗទៀត។ សមាសធាតុគាំទ្រមួយនៃ FTIRM ឆ្នាំ២០១៦-២០២០នឹងបន្តអនុវត្ត ហើយសមាសធាតុថ្មីមួយនឹងត្រូវបានដាក់ឱ្យអនុវត្ត។

## គោលបំណងឬសមាសធាតុទីមួយ ៖ ការសម្រាលកូនដោយឆ្មបជំនាញ

បង្កើនការគ្របដណ្តប់សេវាប្រកបដោយគុណភាពលើការពិនិត្យផ្ទៃពោះយ៉ាងតិច៤ដង ការសម្រាលកូនដោយឆ្មបជំនាញ និងការថែទាំក្រោយសម្រាល ដោយផ្តោតជាពិសេសលើក្រុមងាយរងគ្រោះ។

### សនិទាន

នៅចន្លោះឆ្នាំ២០១៦ ដល់ ឆ្នាំ២០២២ ប្រទេសកម្ពុជាមានវឌ្ឍនភាពយ៉ាងខ្លាំងក្នុងការគ្របដណ្តប់សេវាពិនិត្យផ្ទៃពោះមុនសម្រាល ការសម្រាលកូនដោយឆ្មបជំនាញ ការសម្រាលកូននៅមូលដ្ឋានសុខាភិបាល។ ភាគរយ នៃស្ត្រីដែលបានពិនិត្យផ្ទៃពោះយ៉ាងហោចណាស់ម្តងពីឆ្មបជំនាញបានកើនឡើងពី ៩៦% ក្នុងឆ្នាំ២០១៤ ទៅ ៩៩% ក្នុងឆ្នាំ២០២១-២២។ ការពិនិត្យផ្ទៃពោះយ៉ាងតិច៤ដង បានកើនឡើងពី ៧៦% (ឆ្នាំ២០១៤) ទៅ ៨៦% (ឆ្នាំ២០២១-២២)។ ស្ត្រីប៉ែតសិបប្រាំពីរភាគរយ (៨៧%) បានពិនិត្យផ្ទៃពោះលើកដំបូង នៅក្នុងត្រីមាសទីមួយ នៃការមានផ្ទៃពោះ។ ទោះបីជាយ៉ាងណាក៏ដោយមានភាពខុសគ្នា នៃការទទួលបានសេវាពិនិត្យផ្ទៃពោះយ៉ាងតិច៤ដង រវាងស្ត្រីនៅទីក្រុង និងនៅជនបទ (៩១,៣% ទល់នឹង ៨២,៨%) រវាងស្ត្រីនៅក្នុងក្រុមគ្មានការអប់រំ និងស្ត្រីដែលមានការអប់រំលើសពីមធ្យមសិក្សា (៧១,១% ទល់នឹង ៩៥,៨%) រវាងក្រុមដែលមានប្រាក់ចំណូលទាបបំផុត និងខ្ពស់បំផុត (៧៤,២% ទល់នឹង ៩៥%)។ ស្ត្រីរស់នៅខេត្តរតនគិរីទំនងជាមាន ANC ៤+ តិចជាង (៥៧,៣%) ស្ត្រីរស់នៅខេត្តកំពត (៩១,៩%)។ ស្ត្រីនៅខេត្តក្រចេះទំនងជាទទួលបាន ANC លើកដំបូងរបស់ពួកគេក្នុងអំឡុងត្រីមាសទីមួយតិចជាង (៧៦,៨%) ស្ត្រីរស់នៅខេត្តកំពត (៩៥%)។ ការសម្រាលកូនដោយឆ្មបជំនាញបានកើនឡើងយ៉ាងខ្លាំង ពី ៩៣% (ឆ្នាំ២០១៤) ទៅ ៩៩% (ឆ្នាំ២០២១-២២) ហើយការសម្រាលកូននៅមូលដ្ឋានសុខាភិបាលបានកើនឡើងពី ៨៩% (ឆ្នាំ២០១៤) ទៅ ៩៨% (ឆ្នាំ២០២១-២២)។ ទោះបីជាយ៉ាងណាក៏ដោយ ភាគរយ នៃស្ត្រីដែលទទួលបានការថែទាំក្រោយសម្រាល បានថយចុះពី ៩០% នៅឆ្នាំ២០១៤ ទៅ ៨៥% នៅឆ្នាំ២០២១-២២។ កត្តាមួយក្នុងចំណោមកត្តាជាច្រើននៃការថយចុះនេះគឺដោយសារផលប៉ះពាល់ នៃជំងឺរាតត្បាតសកល កូវីដ១៩ លើការផ្តល់ និងការប្រើប្រាស់សេវានានា។ ជាមួយនឹងភាពប្រសើរឡើងគួរឱ្យកត់សម្គាល់ នៃការគ្របដណ្តប់សេវាថែទាំ ឥឡូវនេះតម្រូវឱ្យមានកិច្ចខិតខំប្រឹងប្រែងក្នុងការបង្កើនគុណភាព នៃការថែទាំដើម្បីកាត់បន្ថយ MMR និង NMR បន្ថែមទៀត។ កិច្ចការនេះទាមទារទាំងយន្តការពង្រឹងគុណភាព (QI) ជាមួយនឹងការពង្រឹងការត្រួតពិនិត្យ ក៏ដូចជាការគាំទ្រសកម្មភាពកែលម្អរួមទាំងការបណ្តុះបណ្តាលក្នុងពេលបំពេញការងារសម្រាប់បុគ្គលិកថែទាំសុខភាព។ សូចនាករមួយចំនួនមានស្រាប់

សម្រាប់តាមដានគុណភាពការថែទាំជាប្រចាំដោយទាញយកទិន្នន័យពី HMIS។ ទិន្នន័យទាំងនេះអាចត្រូវបានពិនិត្យ និងប្រើប្រាស់សម្រាប់សកម្មភាពទាំងនៅថ្នាក់មូលដ្ឋានសុខាភិបាល ស្រុក ខេត្ត និងថ្នាក់ជាតិតាមរយៈផ្ទាំងទិន្នន័យ (dashboard) ។ វាមានសារៈសំខាន់មូលដ្ឋានសុខាភិបាលក្នុងការភ្ជាប់ទិន្នន័យ និងការប្រើប្រាស់ដើម្បីការកែលម្អគុណភាពសម្រាប់មូលដ្ឋានសុខាភិបាលទាំងមូល។

FTIRM ឆ្នាំ២០២៥-២០៣០ មានសារៈសំខាន់ណាស់ក្នុងការថែរក្សាការអនុវត្តល្អ និងត្រូវផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតលើគុណភាព នៃសេវាសុខភាព និងគម្លាត នៃការគ្រប់ដណ្តប់ដែលមិនទាន់បានដោះស្រាយ។ ចាំបាច់ត្រូវបន្តកែលម្អគុណភាព និងការមកតាមកាលវិភាគ នៃការពិនិត្យផ្ទៃពោះមុនសម្រាល ការថែទាំក្រោយសម្រាល ថែទាំពេលសម្រាល និងការថែទាំទារកទើបនឹងកើត ដោយការបង្កើនសមត្ថភាពជំនាញឆ្មប និងមានឆ្មបមធ្យម នៅមណ្ឌលសុខភាព ដើម្បីអាចជួយសង្គ្រោះជីវិតស្ត្រី និងទារកទើបនឹងកើតបានកាន់តែច្រើន។

## អន្តរាគមន៍គន្លឹះ

### ១. ពង្រឹងសមត្ថភាព និងបង្កើនចំនួនឆ្មប

#### ក. ការបណ្តុះបណ្តាលមុនពេលចូលបំរើការងារ

- ពិនិត្យមើលភាពស្របគ្នានៃការអប់រំមុនពេលចូលបំរើការងារជាមួយនឹង MPA និង CPA ដែលបានធ្វើបច្ចុប្បន្នភាពដើម្បីធានាថាសិស្សឆ្មប និងសិស្សផ្សេងទៀតត្រូវបានបំពាក់ដោយចំណេះដឹង និងជំនាញដើម្បីផ្តល់សេវាកម្មសំខាន់ៗដោយផ្អែកលើ MPA និង CPA
- បង្កើត និងអនុវត្តកម្មវិធីសម្រាប់គ្រូបង្រៀន ដើម្បីធានាការបង្រៀន និងការរៀនសូត្រត្រូវបានផ្តល់ប្រកបដោយគុណភាព។ ពង្រឹងបន្ថែមលើការអភិវឌ្ឍសមត្ថភាពគ្រូតាមរយៈកម្មវិធីបណ្តុះបណ្តាលក្នុងពេលបំពេញការងារ និងវគ្គខ្លីៗជាក់លាក់ ស្តីពីការបង្រៀន និងការរៀនសូត្រ ដើម្បីបង្កើនសមត្ថភាពក្នុងការអនុវត្តន៍កម្មវិធីអប់រំផ្អែកលើសមត្ថភាព។
- ធ្វើការវាយតម្លៃតម្រូវការ និងគាំទ្រដល់ការអភិវឌ្ឍន៍ឬការធ្វើបច្ចុប្បន្នភាពសម្ភារៈបង្រៀនសម្រាប់កម្មវិធីបណ្តុះបណ្តាលឆ្មប (កម្មវិធីសិក្សាបរិញ្ញាប័ត្ររងឆ្មប (ADM) បីឆ្នាំ និង បរិញ្ញាប័ត្រឆ្មប (BSM) បួនឆ្នាំ និងវគ្គបណ្តុះបណ្តាលបន្តពីឆ្មបបឋម ទៅ ADM និងពីឆ្មបមធ្យម (ADM) ទៅ BSM។
- ពិចារណាបញ្ចប់កម្មវិធីសិក្សាឆ្មបរយៈពេលមួយឆ្នាំពីបរិញ្ញាបត្រគិលានុបដ្ឋាកឆ្មប(BDNM) ។

#### ខ. ចំនួនឆ្មបដែលមាន (AVAILABILITY)

- ធ្វើការវិភាគទីផ្សារការងារក្នុងវិស័យសុខាភិបាល
- អនុវត្តផែនការអភិវឌ្ឍន៍ធនធានមនុស្សសុខាភិបាល ឆ្នាំ២០២៤-២០៣៣
- ជ្រើសរើសឆ្មបមធ្យមទើបចេញពីសាលាឱ្យចូលបម្រើការងារ ចំនួន ៣០០ នាក់ក្នុងមួយឆ្នាំ (សម្រាប់មូលដ្ឋានសុខាភិបាលសាធារណៈ) ដើម្បីបំពេញតម្រូវការឆ្មបនៅតាមមណ្ឌលសុខភាពដែលនៅសល់ (មណ្ឌលសុខភាពចំនួន ២១៦ កន្លែង មានឆ្មបមធ្យមតែម្នាក់ប៉ុណ្ណោះ) និងសម្រាប់មណ្ឌលសុខភាពបង្កើតថ្មី (ចំនួនមណ្ឌលសុខភាពមានការកើនឡើងជារៀងរាល់ឆ្នាំ) និងសម្រាប់បំពេញនូវឆ្មបចូលនិវត្តន៍។

- ស្វែងរកជម្រើស នៃការចុះកិច្ចសន្យាឆ្មបមធ្យមនៅមណ្ឌលសុខភាពតាមតំបន់ដាច់ស្រយាល ឬផ្តល់អាទិភាពឬឱកាសដល់ឆ្មបនៅ នឹងមូលដ្ឋានឆ្មបជនជាតិដើមភាគតិច ឱ្យធ្វើការនៅភាគពព្យសាន។

### គ. បទប្បញ្ញត្តិ និងការផ្តល់អាជ្ញាបណ្ណ (REGULATION AND LICENSING)

- ត្រួតពិនិត្យរចនាសម្ព័ន្ធ នៃគណៈឆ្មបកម្ពុជា (CMC) នៅថ្នាក់កណ្តាល និងស្វែងរកមតិគាំទ្រឬប្រមូលផ្តុំធនធានបន្ថែមទៀត ដើម្បីអនុញ្ញាតឱ្យមានការបំពេញតួនាទីរបស់ CMC រួមទាំងធនធានមនុស្សផងដែរ
- ពិនិត្យភាពស្របគ្នារវាងក្របខ័ណ្ឌបទប្បញ្ញត្តិ និង MPA និង CPA ដែលបានធ្វើបច្ចុប្បន្នភាព ដើម្បីធានាបាននូវការគាំទ្រផ្នែកច្បាប់ និងការការពារសម្រាប់ឆ្មប និងប្រភេទបុគ្គលិកដទៃទៀត ដើម្បីផ្តល់សេវាកម្មសំខាន់ៗប្រកបដោយគុណភាពដោយផ្អែកលើ MPA និង CPA ។
- បន្តការចុះឈ្មោះឆ្មប និងការផ្តល់អាជ្ញាប័ណ្ណឆ្មបតាមអនឡាញ
- បន្តការបន្តអាជ្ញាប័ណ្ណឆ្មប ស្របតាមស្តង់ដាអប្បបរមាសម្រាប់ការបន្តអភិវឌ្ឍន៍វិជ្ជាជីវៈឆ្មប។

## ២. ការបណ្តុះបណ្តាលក្នុងពេលចូលបំរើការងារ (IN-SERVICE TRAINING) ដើម្បីបង្កើនគុណភាព និងត្រូវតាមកាលវិភាគ នៃការថែទាំមុនពេលសម្រាល ការថែទាំក្នុងអំឡុងពេលសម្រាល និងក្រោយសម្រាល

ក- បន្តអនុវត្តការបណ្តុះបណ្តាលក្នុងពេលចូលបំរើការងារ និងការបង្វឹកនៅនឹងកន្លែង ដល់បុគ្គលិកគ្រប់រូបដែលផ្តល់សេវាថែទាំមាតា និងទារកទើបនឹងកើត

ខ- ធ្វើការវាយតម្លៃអំពីតម្រូវការ នៃការបណ្តុះបណ្តាល ស្តីពី BEmONC សម្រាប់បរិញ្ញាបត្រ គិលានុបដ្ឋាក-ឆ្មប (BDNMs) ដែលបច្ចុប្បន្ន កំពុងបំពេញការងារជាឆ្មបនៅតាមមូលដ្ឋានសុខាភិបាល និងផ្តល់ការបណ្តុះបណ្តាលក្នុងអំឡុងពេលបំពេញការងារឬការហ្វឹកហាត់ ស្តីពី BEmONC

គ- រៀបចំវគ្គខ្លី ស្តីពីការគ្រប់គ្រង និងភាពជាអ្នកដឹកនាំសម្រាប់ឆ្មប។

ឃ- អនុវត្តការកែលម្អគុណភាពនៅកន្លែងធ្វើការ ការវាយតម្លៃអំពីគុណភាព និងតម្រូវការសម្រាប់ការកែលម្អគុណភាព និងការទទួលសេវាតាមកាលវិភាគ នៃការពិនិត្យផ្ទៃពោះមុនសម្រាល ការសម្រាល និងក្រោយសម្រាលស្របតាមគោលការណ៍ណែនាំជាតិ (រួមទាំងការទទួលបានការណែនាំពីអាហារូបត្ថម្ភ និងជាតិដែក ការប្រើ MgSO4 ការផ្តល់ cortico steroid សម្រាប់ស្ត្រីមានផ្ទៃពោះតាមការចាំបាច់) និងភ្ជិតគម្លាតរវាងខេត្តនានាកម្រិតវប្បធម៌ កម្រិតជីវភាព។

## ៣. ពង្រឹងយន្តការត្រួតពិនិត្យ និងកែលម្អគុណភាព ដើម្បីបង្កើនគុណភាព នៃការថែទាំ

ក- ពង្រឹងការត្រួតពិនិត្យជាប្រចាំនូវគុណភាព នៃការថែទាំមាតា និងទារកតាមរយៈការចាប់ផ្តើមប្រើផ្ទាំងទិន្នន័យ (dash board) និងប្រើប្រាស់ទិន្នន័យសម្រាប់ទាំងកម្រិតមូលដ្ឋាន និងថ្នាក់ជាតិ

ខ- គាំទ្រមូលដ្ឋានសុខាភិបាលដើម្បីពង្រឹងយន្តការកែលម្អគុណភាពជាបន្តបន្ទាប់ និងអនុវត្តផែនការកែលម្អ

## គោលបំណង ឬ សមាសធាតុទីពីរ៖ សេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និង ថែទាំទារក ទើបនឹងកើត (EMONC) និងការពិនិត្យមរណភាពមាតា និង ទារកជុំវិញកំណើត និងការឆ្លើយតប (MPDSR)

ខណៈពេលដែលការមានផ្ទៃពោះ និងការសម្រាលកូនភាគច្រើនធម្មតា ប្រហែល ១៥% នៃស្ត្រីមានផ្ទៃពោះ បានវិវត្តន៍ទៅជាលក្ខខណ្ឌដែលអាចគំរាមកំហែងដល់អាយុជីវិតដែលតម្រូវឱ្យមានសេវា EmONC ដោយខ្លះត្រូវ ការបញ្ជូនទៅកាន់កម្រិតខ្ពស់ នៃការថែទាំ។ FTIRM មានគោលបំណងកែលម្អការគ្រប់ដណ្តប់ នៃសេវាសង្គ្រោះបន្ទាន់ ផ្នែកសម្ភព និងថែទាំទារកទើបនឹងកើត ដើម្បីបំពេញតាមស្តង់ដាដែលត្រូវមានមូលដ្ឋាន EmONC យ៉ាងតិច ៥ សម្រាប់ប្រជាជន ៥០០ ០០០ នាក់ (ជាពិសេស មូលដ្ឋាន BEmONC) និងពង្រឹងប្រព័ន្ធបញ្ជូន និងការពិគ្រោះ ពីចម្ងាយ។ ឯកសារនេះក៏មានគោលបំណងពង្រឹងការពិនិត្យមរណភាពមាតា និងទារកជុំវិញកំណើត និងការ ឆ្លើយតប (MPDSR) ដោយភ្ជាប់វាជាមួយនឹងគំនិតផ្តួចផ្តើមកែលម្អគុណភាព។

### សនិទាន

នៅក្នុងឆ្នាំ ២០២០ ការពិនិត្យតាមដានផែនការកែលម្អ EmONC បានផ្តល់ព័ត៌មានថា មានមូលដ្ឋាន BEmONC ដែលដំណើរការ ចំនួន ៤៥ និងមូលដ្ឋាន CEmONC ដែលដំណើរការ ចំនួន ៣៥ ក្នុងរយៈពេល ៣ ខែ មុនពេលវាយតម្លៃ ឬមានមូលដ្ឋាន BEmONC ដែលដំណើរការ ចំនួន ៧១ និងមូលដ្ឋាន CEmONC ដែលដំណើរការ ចំនួន ៤០ ក្នុងរយៈពេល ១២ ខែមុនពេលវាយតម្លៃ។ ការវាយតម្លៃក៏បានបង្ហាញអំពីវិសមភាពក្នុងការផ្តល់សេវា EmONC និងបានរកឃើញផងដែរថា នៅមានបញ្ហាប្រឈម នៃការគ្រប់ដណ្តប់នៅក្នុងមូលដ្ឋាន EmONC ប្រសិនបើ ប្រៀបធៀបនឹងចំណុចគោល នៃស្តង់ដារបស់អង្គការសហប្រជាជាតិ និងផែនការកែលម្អ EmONC ឆ្នាំ២០១៦-២០២០ (មិនមានគម្លាតសម្រាប់ CEmONC និង មានគម្លាតសម្រាប់ BEmONC ចំនួន ៧៤ ធៀបនឹងស្តង់ដា របស់អង្គការសហប្រជាជាតិ និងគម្លាតនៅក្នុង CEmONC ចំនួន ១៣ និង BEmONC ចំនួន ៨៨ធៀបនឹងផែនការ កែលម្អ EmONC) ។ មូលដ្ឋាន EmONC ចំនួន ៦៣ ក្នុងចំណោមមូលដ្ឋានដែលត្រូវបានវាយតម្លៃ ចំនួន១៨១ មានគ្រួសារ ដែលរស់នៅទីកន្លែងដែលត្រូវធ្វើដំណើរលើសពី ២ ម៉ោងពីមូលដ្ឋានទាំងនេះ។ វឌ្ឍនភាពត្រូវបានបង្ហាញ តាមរយៈការកើនឡើង នៃចំនួនបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាល រួមមាន អ្នកឯកទេស គ្រូពេទ្យឆ្មប អ្នក ប្រើថ្នាំស្ពឹក ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន បរិក្ខារវេជ្ជសាស្ត្រ ឱសថ សម្ភារៈប្រើប្រាស់ និងឧបករណ៍សម្រាប់បង្ការ និង ត្រួតពិនិត្យ ការចម្លងរោគនៅគ្រប់មូលដ្ឋាន EmONC ដែលដំណើរការ។ ទោះបីជាយ៉ាងណាក៏នៅមានតម្រូវការដ៏ធំ ក្នុងការកែលម្អស្ថានភាពរបស់មូលដ្ឋានដែលមិនដំណើរការឱ្យទៅជាមូលដ្ឋានដែលដំណើរការ។

ការស្រាវជ្រាវមរណភាពមាតា (MDA) បានចាប់ផ្តើមនៅប្រទេសកម្ពុជាក្នុងឆ្នាំ២០០៤។ ពាក្យនេះត្រូវបាន ប្រើនៅក្នុងប្រទេសកម្ពុជាដើម្បីសំដៅលើដំណើរការតាមដានមរណភាពមាតា និងការឆ្លើយតបនាពេលបច្ចុប្បន្ន។ ដោយមានការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីអង្គការសុខភាពពិភពលោកមជ្ឈមណ្ឌល ជាតិគាំពារមាតា និងទារកបានរៀបចំការពិនិត្យឡើងវិញថ្នាក់ជាតិចំនួនពីរលើក នៅឆ្នាំ២០១១ និង ឆ្នាំ២០១៨។

ការពិនិត្យនេះបានរកឃើញមូលហេតុចម្បងៗចំនួនពីរ (ការធ្លាក់ឈាមក្រោយពេលសម្រាល និងក្រឡាភ្លើង) នៃមរណភាពមាតា និងតម្រូវឱ្យមានជំនាញសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងការថែទាំទារកទើបកើត ដើម្បីកាត់បន្ថយមរណភាពមាតាបន្ថែមទៀត។ ក្នុងការស្រាវជ្រាវមរណភាពមាតា ក៏នៅមានបញ្ហាប្រឈមក្នុងការកំណត់ឬមិនអាចធ្វើចំណាត់ថ្នាក់ ការកត់ត្រា និងការរាយការណ៍អំពីមូលហេតុនៃមរណភាព និងការផ្តល់មតិត្រឡប់ទៅគណៈកម្មាការស្រាវជ្រាវមរណភាពមាតាថ្នាក់ខេត្ត មិនមានទិន្នន័យអំពីលទ្ធផល នៃមរណភាពទារកជុំវិញកំណើត គុណភាពនៃការថែទាំ និងបញ្ហាក្នុងការបញ្ជូនទៅផ្នែកសង្គ្រោះបន្ទាន់។ គុណភាព នៃអនុសាសន៍របស់គណៈកម្មាការស្រាវជ្រាវមរណភាពមាតា នៅតែជាកង្វល់ដ៏ធំមួយ នៅខណៈពេលដែលអនុសាសន៍ជាក់លាក់ត្រូវបានលើកឡើងក្នុងអំឡុងពេលកិច្ចប្រជុំតែមិនត្រូវបានឆ្លុះបញ្ចាំងនៅក្នុងរបាយការណ៍ជាលាយលក្ខណ៍អក្សរនោះទេ។ មានករណីមរណភាពមាតាដែលអាចមិនត្រូវបានរាយការណ៍ក្នុងការស្រាវជ្រាវមរណភាពមាតា MDSR ប្រសិនបើប្រៀបធៀបនឹងចំនួនប៉ាន់ស្មានដែលត្រូវគណនាចេញពីអត្រាមរណភាពមាតា (MMR) និងចំនួនកំណើតរស់តាមទិន្នន័យប៉ាន់ស្មានដោយទីភ្នាក់ងារអង្គការសហប្រជាជាតិ។

FTIRM ២០២៥-២០៣០ បន្តផ្តោតលើការធ្វើឱ្យប្រសើរឡើងនូវគុណភាព និងការគ្របដណ្តប់របស់ EmONC ការកសាងសមត្ថភាពបុគ្គលិកពាក់ព័ន្ធដែលកំពុងបំពេញការងារនៅតាមមូលដ្ឋាន EmONC ការស្វែងរកការគាំទ្រពីអាជ្ញាធរខេត្តសម្រាប់ការគាំទ្របន្ថែមលើការធ្វើផែនការ និងការអនុវត្តផែនការកែលម្អ EmONC ថ្នាក់ខេត្ត និងការបញ្ជូនករណីសង្គ្រោះបន្ទាន់ និងទាន់ពេលវេលា ទៅកាន់មូលដ្ឋានសុខាភិបាលសមស្របដើម្បីសង្គ្រោះជីវិត។ លើសពីនេះ ពិធីសារជាតិស្រាវជ្រាវមរណភាពមាតានឹងត្រូវធ្វើបច្ចុប្បន្នភាពដោយបន្ថែមនូវការពិនិត្យមរណភាពទារកជុំវិញកំណើត និងការភ្ជាប់រវាងការពិនិត្យនិងការធ្វើសកម្មភាពឆ្លើយតប និងសារសំខាន់ នៃការអនុវត្តផែនការកែលម្អគុណភាព។

## អន្តរាគមន៍គន្លឹះ

### ១. កែលម្អគុណភាព និងការគ្របដណ្តប់នៃ EmONC

ក- បង្កើនការគ្របដណ្តប់របស់ BEmONC ដើម្បីផែនការកែលម្អ EmONC ឆ្នាំ២០២១-២០២៥ (ដើម្បីឈានដល់គោលដៅមានមូលដ្ឋាន EmONC យ៉ាងតិច ១៨០)

ខ- ពង្រឹងគុណភាពរបស់មូលដ្ឋាន EmONC ដែលដំណើរការ រួមទាំងការបណ្តុះបណ្តាលពង្រឹងជំនាញការតាមដានការបណ្តុះបណ្តាល និងការបង្វឹកនៅនឹងកន្លែង

គ- បំពាក់បរិក្ខារពេទ្យ ឱសថ បរិក្ខារ និងសម្ភារៈបង្ការការចម្លងរោគ នៅមូលដ្ឋាន EmONC។

ឃ- ពង្រឹងបណ្តាញថែទាំ ជាមួយនឹងការបញ្ជូនបន្តប្រកបដោយសុវត្ថិភាព និងទាន់ពេលវេលា

### ២. ការគូរផែនទីមូលដ្ឋាន EmONC

ធ្វើការពិនិត្យផែនការកែលម្អសេវា EmONC បន្ទាប់ទៀត ឬការវាយតម្លៃទ្រង់ទ្រាយតូច ដែលរួមបញ្ចូលមូលដ្ឋានឯកជនផងដែរ។

### ៣. កែលម្អការកត់ត្រា និងការរាយការណ៍ទិន្នន័យសេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព

ក- កំណត់ស្តង់ដា និយមន័យ នៃផលវិបាកផ្នែកសម្ភព ទារកស្លាប់កើត និងផលវិបាកដទៃទៀត យោងតាមការចាត់ថ្នាក់ជំងឺជាអន្តរជាតិ (ICD ១១)

ខ- កែលម្អការកត់ត្រា និងការរាយការណ៍អំពីសេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងស្វែងយល់អំពីលទ្ធភាពក្នុងការបញ្ចូលទិន្នន័យដែលមិនបានរាយការណ៍ទៅក្នុងប្រព័ន្ធព័ត៌មានសុខាភិបាល។

### ៤. ស្វែងរកមតិគាំទ្រសម្រាប់ការគាំទ្រសេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភពបន្ថែមទៀតដោយការភ្ជាប់បណ្តាញថៃទាំដែលរឹងមាំ

ក- ស្វែងរកមតិគាំទ្រពីអាជ្ញាធរខេត្ត និងភាគីពាក់ព័ន្ធទាំងអស់ សម្រាប់ការគាំទ្របន្ថែមទៀតលើការរៀបចំផែនការ និងការអនុវត្តផែនការកែលម្អសេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព ថ្នាក់ខេត្ត (រួមទាំងធនធានហិរញ្ញវត្ថុផងដែរ)

ខ- ស្វែងរកមតិគាំទ្រសម្រាប់ជំនួយក្នុងការបញ្ជូនករណីសង្គ្រោះបន្ទាន់ទៅកាន់មូលដ្ឋានសុខាភិបាលបានទាន់ពេលវេលា ដើម្បីសង្គ្រោះជីវិត

គ- ចូលរួមជាមួយវិស័យឯកជន ដើម្បីគាំទ្រការពង្រឹងសេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព ។

### ៥. ការសម្រាលកូនដោយវះកាត់

ក- ធ្វើការវិភាគអំពីកត្តាជំរុញ នៃអត្រាសម្រាលកូនដោយវះកាត់ ទាំងតម្រូវការខ្ពស់ដែលមិនបានបំពេញ និងការផ្តល់សេវាច្រើនហួស និងផ្តល់អនុសាសន៍ដើម្បីកែលម្អបន្ថែមទៀត

ខ- ពង្រឹងការអនុវត្តស្តង់ដាការព្យាបាល "ការវះកាត់ដោយមានហេតុផលសមស្រប" (ការវះកាត់ដែលមានលក្ខខណ្ឌតម្រូវផ្នែកវេជ្ជសាស្ត្រ) ឬការប្រើ "ចំណាត់ថ្នាក់ **Robson**" សម្រាប់ការវះកាត់ ជាពិសេសនៅតាមសេវាឯកជន និងនៅទីក្រុង។

### ៦. ពិចារណាបញ្ចូលការពិនិត្យមរណភាពទារកជុំវិញកំណើតមរណភាពទារកទើបនឹងកើត និងករណីមានផលវិបាកហើយត្រូវបានសង្គ្រោះ (NEAR MISS).

ក- កែសម្រួលពិធីសារជាតិស្រាវជ្រាវមរណភាពមាតា ដើម្បីរួមបញ្ចូលការពិនិត្យមរណភាពទារកជុំវិញកំណើត។

ខ- ការពង្រឹងសមត្ថភាពថ្នាក់ខេត្ត និងមូលដ្ឋានសុខាភិបាលលើការអនុវត្ត **MPDSR** ។

ប្រមូលផ្តុំការគាំទ្រ(អ្នកជំនាញផ្នែកព្យាបាលអ្នកឯកទេសមន្ត្រីជាន់ខ្ពស់ផ្នែកសុខភាពសាធារណៈ)សម្រាប់ការកសាងសមត្ថភាពរបស់សមាជិកគណៈកម្មការ **MPDSR** នៅថ្នាក់ខេត្ត និងនៅមូលដ្ឋានសុខាភិបាល ដើម្បីកំណត់អត្តសញ្ញាណរាយការណ៍ កត់ត្រាមូលហេតុ នៃការស្លាប់ លទ្ធផលជុំវិញកំណើត និងគុណភាពនៃការថែទាំ និងផ្តល់អនុសាសន៍។

គ- អនុវត្ត **MPDSR** ចំពោះករណីមានផលវិបាកហើយត្រូវបានសង្គ្រោះ ហើយប្រើលទ្ធផលដើម្បីផ្តល់មតិកែលម្អក្នុងអំឡុងពេលកិច្ចប្រជុំ **MCAT** និងដើម្បីបង្កើតករណីសិក្សាសម្រាប់ការបង្វឹក។

ឃ- ស្វែងយល់ពីវិធីសាស្ត្រ **sensitive** ក្នុងការប៉ាន់ប្រមាណឬការគណនាសមាមាត្រមរណភាពមាតាក្នុងករណី **CDHS** នាពេលអនាគតមិនបញ្ចូលម៉ូឌុលមរណភាពមាតា។

## គោលបំណង ឬ សមាសធាតុទីបី៖ ការថែទាំទារកទើបនឹងកើត

ដើម្បីពង្រឹងគុណភាព និងការគ្របដណ្តប់ នៃការថែទាំជាសារវ័ន្តទារកទើបនឹងកើត (EENC) (ការថែទាំទារកទើបនឹងកើតភ្លាម (INC) និងការថែទាំទារកដែលមានតម្រូវការពិសេស) ។

### សនិទាន

ក្នុងចន្លោះឆ្នាំ២០១៦ ដល់ ឆ្នាំ២០២២ វឌ្ឍនភាពបានកើតមានឡើងតាមរយៈការរៀបចំគោលការណ៍ណែនាំ និងឧបករណ៍សម្រាប់ការអនុវត្ត និងវឌ្ឍនភាពក្នុងការកសាងសមត្ថភាពរបស់បុគ្គលិកសុខាភិបាល ដែលកំពុងបំពេញការងារនៅក្នុងមន្ទីរពេទ្យ និងមណ្ឌលសុខភាពទូទាំងប្រទេស។ របាយការណ៍វឌ្ឍនភាពរៀងរាល់ពីរឆ្នាំម្តង លើកទី៣ (ឆ្នាំ២០១៨-២០២០) បានបង្ហាញថា នៅកម្ពុជាបុគ្គលិកសុខាភិបាល៧៦% (៤២១៦/៥៥៧៨) បានទទួលការបង្វឹក ហើយមូលដ្ឋានសុខាភិបាល ៨៩% (១១៨៧/១៣២៨) កំពុងអនុវត្តការ EENC។ មកទល់បច្ចុប្បន្នមានក្រុមការងារថែទាំជាសារវ័ន្តទារកទើបនឹងកើតនៅក្នុងមន្ទីរពេទ្យ (EENC-HCTs) ចំនួន ២៩ ដែលកំពុង ដំណើរការ នៅក្នុងមន្ទីរពេទ្យជាតិចំនួន ២មន្ទីរពេទ្យខេត្តចំនួន ២៥ និងមន្ទីរពេទ្យបង្អែកស្រុកចំនួន ២ ដើម្បីត្រួតពិនិត្យ និងធានាគុណភាពរបស់ EENC នៅមន្ទីរពេទ្យ។ ការអនុវត្ត EENC ធ្វើចំពោះគ្រប់ការសម្រាលកូនទាំងអស់ រួមទាំងការសម្រាលកូនដោយផ្ទៃវះកាត់ផងដែរ។នៅឆ្នាំ២០២២មានមន្ទីរពេទ្យចំនួន៣០នៅកម្ពុជាមានបុគ្គលិកដែលបានទទួលការបង្វឹក និងអនុវត្តការថែទាំទារកតាមរបៀបម្តាយកង់ហ្គូរូ (KMC)។ គោលការណ៍ណែនាំ និងឧបករណ៍នានាត្រូវបានធ្វើបច្ចុប្បន្នភាពរួមជាមួយអនុសាសន៍ថ្មីៗរបស់អង្គការសុខភាពពិភពលោក និងមានជាស្រេចសម្រាប់ការប្រើប្រាស់រួមទាំងការជួយគាំទ្រដល់ម្តាយបំបៅកូនដោយទឹកដោះម្តាយ ការច្របាច់ទឹកដោះ និងបញ្ចុកទឹកដោះម្តាយ។ ម៉្យាងវិញទៀត ការកែលម្អគុណភាពក៏ត្រូវបានពង្រឹងតាមរយៈគំរោង HEQIP/CNP នៅតាមមូលដ្ឋានសុខាភិបាល និងការកសាងសមត្ថភាពសមាជិកឃុំឬសង្កាត់ ដើម្បីគាំទ្រដល់ស្ត្រី និងកុមារ ក្នុងការបំបៅកូនដោយទឹកដោះម្តាយ ការផ្តល់អាហារ និងអាហារបំប៉នដល់ទារក និងកុមារតូចឱ្យកាន់តែប្រសើរឡើង។ ការបណ្តុះបណ្តាលអំពីការផ្តល់សេវាដទៃទៀត ស្តីពីការថែទាំមាតានិងកុមារ សម្រាប់ឆ្មប គ្រូពេទ្យ និងបុគ្គលិកដទៃទៀត បានរួមបញ្ចូលនូវចំណេះដឹង និងជំនាញក្នុងការបំបៅកូនដោយទឹកដោះម្តាយ ដើម្បីពង្រឹងការអនុវត្តក្នុងការបំបៅកូនដោយទឹកដោះម្តាយ។

ទោះបីជាយ៉ាងណាក៏ដោយ លទ្ធផលពី CDHS បានបង្ហាញរូបភាពចម្រុះ។ នៅខណៈពេលដែលស្ត្រី ៩៧,៨% បានសម្រាលកូននៅមូលដ្ឋានសុខាភិបាលនោះ ក្នុងចំណោមពួកគេ មានតែ ៧៦,៨% ប៉ុណ្ណោះ ដែលទទួលបានជំនួយភ្លាមៗក្នុងការដាក់ទារកទើបនឹងកើតនៅលើទ្រូងម្តាយ ។ មានម្តាយនិងទារកតែ ៧៥,៣% ប៉ុណ្ណោះ ដែលបានទទួលការថែទាំក្រោយសម្រាល(សម្រាប់ទាំងពីរនាក់)ក្នុងរយៈពេល២ថ្ងៃក្រោយពេលសម្រាល និងមានទារកទើបនឹងកើតតែ ៤៩,៦% ប៉ុណ្ណោះ ដែលបានទទួលការ អនុវត្ត៥ ចំនុច (ការត្រួតពិនិត្យទងសុក ការវាស់សីតុណ្ហភាព ម្តាយបានប្រាប់អំពីរបៀបមើលថាតើទារកត្រូវការការថែទាំវេជ្ជសាស្ត្រភ្លាមៗដែរ ឬទេ ម្តាយបានទទួលពិគ្រោះយោបល់អំពីការបំបៅកូនដោយទឹកដោះម្តាយ និងម្តាយបានសង្កេតមើលការបំបៅកូនដោយទឹកដោះម្តាយ)។ ម្តាយតែ ៥២,៦% ប៉ុណ្ណោះ បានទទួលការពិគ្រោះយោបល់អំពីការបំបៅកូនដោយទឹកដោះម្តាយ និងបានសង្កេតមើលការបំបៅកូនដោយទឹកដោះម្តាយ។ ការអនុវត្តនៅកម្រិតទាបនេះបាននាំឱ្យមានការថយចុះ នៃការចាប់ផ្តើមបំបៅកូនដោយទឹកដោះម្តាយភ្លាមៗ និងការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់។

បញ្ហាប្រឈមមួយទៀតគឺទារកទើបនឹងកើតទំនងជាស្លាប់ក្នុងរយៈពេល ៧ ថ្ងៃក្រោយពេលកើត (មរណភាពរបស់ទារកទើបនឹងកើតដំបូងគឺ ៧ ករណីក្នុង ១០០០ កំណើតរស់) ច្រើនជាងក្នុងរយៈពេល ៣ សប្តាហ៍ក្រោយ (អត្រាមរណភាពទារកទើបនឹងកើតគឺ ៨ ករណីក្នុង ១០០០ កំណើតរស់)។ ដូច្នេះ ការថែទាំក្នុងអំឡុងពេលសម្រាល និងទារកទើបនឹងកើតមានសារសំខាន់ណាស់ក្នុងការកាត់បន្ថយមរណភាពទារកទើបកើត។

FTIRM ២០២៥-២០៣០ ផ្តោតលើការបន្តបណ្តុះបណ្តាលឬការបង្ហាត់បង្រៀនស្តីពី EENC ដល់មូលដ្ឋានសុខាភិបាលដែលនៅសល់ បង្កើន KMC សម្រាប់ទារកកើតមិនគ្រប់ខែ និងមានទម្ងន់ទាប បណ្តុះបណ្តាលអំពីការឆ្លងមេរោគក្នុងឈាមទារកទើបនឹងកើត ពង្រឹងដំណើរការកែលម្អគុណភាព EENC និងលើកកម្ពស់ការអនុវត្តក្នុងការបំបៅកូនដោយទឹកដោះម្តាយ។

**អន្តរាគមន៍គន្លឹះ**

**១. បង្កើនការគ្របដណ្តប់ នៃមូលដ្ឋានសុខាភិបាលដែលមានបុគ្គលិកទទួលបានការបណ្តុះបណ្តាលនៅក្នុងកញ្ចប់ EENC (ការថែទាំទារកទើបនឹងកើតភ្លាម ការថែទាំតាមបែបម្តាយកង់ហ្គូរូ ការបំបៅដោះកូនដោយទឹកដោះម្តាយ ការឆ្លងមេរោគនៅក្នុងឈាមទារកទើបនឹងកើត)**

ក- បន្តការបណ្តុះបណ្តាលនៅពេលធ្វើការ និងការបង្វឹកនៅនឹងកន្លែងដល់បុគ្គលិកដែលធ្វើការនៅមន្ទីរសម្ភព NCU និងមណ្ឌលសុខភាព អំពី EENC និង KMC ភ្លាមៗ ក្រោយពេលសម្រាល សម្រាប់ទារកកើតមិនគ្រប់ខែ និងមានទម្ងន់ទាប

ខ- បន្តការបណ្តុះបណ្តាលសម្រាប់បុគ្គលិកសុខាភិបាលអំពីការថែទាំទារកទើបនឹងកើត និងក្រោយសម្រាលស្របតាមគោលការណ៍ណែនាំសម្រាប់កែលម្អ EENC នៅមូលដ្ឋានសុខាភិបាល និងក្នុងពិធីសារជាតិមាតុភាពគ្មានគ្រោះថ្នាក់

គ- ធ្វើសមាហរណកម្មកញ្ចប់ EENC នៅក្នុងកម្មវិធីសិក្សាដោយផ្អែកលើសមត្ថភាពជំនាញ (CBE) មុនពេលចូលបំរើការងារ សម្រាប់និស្សិតពេទ្យ គិលានុបដ្ឋាក និងឆ្មប

ឃ- បង្កើនចំណេះដឹង និងជំនាញលើការថែទាំទារកទើបនឹងកើត និងកញ្ចប់ EENC ដល់បុគ្គលិកបណ្តុះបណ្តាលគ្រូបង្រៀន គ្រូណែនាំផ្នែកគ្លីនិកនិងគណៈគ្រប់គ្រង នៃសកលវិទ្យាល័យវេជ្ជសាស្ត្រសុខាភិបាល និងសាលាបណ្តុះបណ្តាលវេជ្ជសាស្ត្រភូមិភាគ ។

**២. ពង្រឹងគុណភាព EENC, KMC និងបង្កើនចំនួនមូលដ្ឋានដែលមាន EENC-HCT**

ក- កែលម្អគុណភាព នៃកញ្ចប់ EENC នៅមន្ទីរពេទ្យ និង INC, KMC ការអនុវត្តក្នុងការបំបៅកូនដោយទឹកដោះម្តាយនៅមណ្ឌលសុខភាព

ខ- បំពាក់សម្ភារៈសារវន្តសម្រាប់ EENC ដល់គ្រប់មណ្ឌលសុខភាពទាំងអស់

គ- បង្កើត EENC-HCT ដោយផ្អែកលើ "គោលការណ៍ណែនាំសម្រាប់ការកែលម្អគុណភាពនៃការថែទាំជាសារវន្តសម្រាប់ទារកទើបនឹងកើត នៅមណ្ឌលសុខភាព - ឆ្នាំ២០២២" នៅមន្ទីរពេទ្យជាតិដែលនៅសល់មន្ទីរពេទ្យ CPA២ និង CPA១

ឃ- បំពាក់ និងបង្កើត "ផ្នែកថែទាំទារក (NCU) កម្រិត ២"[14] នៅមន្ទីរពេទ្យកម្រិត CPA៣[15] ។

ង- ពង្រីកវិសាលភាពទិន្នន័យ EENC ក្នុងប្រព័ន្ធព័ត៌មានសុខាភិបាល DHIS-២ តាមដាន និងផ្សព្វផ្សាយទិន្នន័យ EENC សម្រាប់ការកែលម្អការថែទាំទារកទើបនឹងកើត។

## ៣. ការថែទាំទារកទើបនឹងកើតដែលមានជំងឺ

ក- គ្រប់គ្រងទារកទើបនឹងកើតដែលមានការឆ្លងមេរោគក្នុងឈាម ពិបាកដកដង្ហើម ថយចុះជាតិស្ករក្នុងឈាម និងការថែទាំទារកទើបនឹងកើតដែលមានជំងឺ រួមទាំងទារកកើតមិនគ្រប់ខែឬទារកមានទម្ងន់ទាប នៅមន្ទីរពេទ្យខេត្ត

ខ- បន្តកែលម្អ និងពង្រឹងការបញ្ជូនទារកទើបនឹងកើតដែលមានជំងឺ ទៅកាន់មូលដ្ឋានសុខាភិបាលឯកទេស។ ធានារថយន្តគិលានសង្គ្រោះមានបុគ្គលិកមានជំនាញ និងបំពាក់សម្ភារៈវេជ្ជសាស្ត្រពេញលេញដើម្បីផ្តល់ការគាំទ្រក្នុងអំឡុងពេលបញ្ជូន។

## ៤. ភាពជាដៃគូរ វាងវិស័យសាធារណៈ និងឯកជន ដើម្បីកែលម្អ EENC និងការបំបៅកូនដោយទឹកដោះម្តាយនៅគ្លីនិកឯកជន

ក- ធានាថា គ្លីនិកសម្ភពឯកជនទាំងអស់អនុវត្តគោលការណ៍ណែនាំថ្នាក់ជាតិ

ខ- ស្វែងរកយន្តការដើម្បីកែលម្អគុណភាពសេវាកម្មនៅតាមមូលដ្ឋានឯកជន ដែលមានសម្ភព និងផ្នែកថែទាំទារកហើយប្រសិនបើអាចធ្វើបាន ផ្តល់ការបណ្តុះបណ្តាលអំពីកញ្ចប់ EENC ដល់អ្នកផ្តល់សេវាកម្ម និងបង្កើតក្រុមការងាររបស់មន្ទីរពេទ្យ។

---

[14] NCU កម្រិត ២ ត្រូវបានកំណត់និយមន័យថាជា NCU ដែលមានការថែទាំដូចតទៅ៖ KMC CPAP ការផ្តល់អាហារ និងការព្យួរសេរ៉ូមដោយមានជំនួយ ការគ្រប់គ្រងការឆ្លងមេរោគក្នុងឈាមទារកទើបនឹងកើត ជំងឺខាន់លឿង ជំងឺរលាកខួរក្បាល ការរកឃើញ ឬការបញ្ជូនភាពមិនប្រក្រតីពីកំណើតការតាមដានទារកទើបនឹងកើតដែលមានហានិភ័យ ការព្យាបាលដោយការប្តូរឈាម។ ប្រភព៖ ការបញ្ឈប់មរណភាពទារកទើបនឹងកើត និងទារកកើតស្លាប់ ដែលអាចទប់ស្កាត់បាន ត្រឹមឆ្នាំ២០៣០. ខែកក្កដា ឆ្នាំ ២០២០. WHO និង Unicef.

[15] គោលការណ៍ណែនាំ ស្តីពីសំណុំសកម្មភាពបង្គ្រប់សម្រាប់ការអភិវឌ្ឍន៍មន្ទីរពេទ្យបង្អែក ខែមិថុនា ឆ្នាំ២០១៤. MoH. នៅឆ្នាំ២០២២ មាន ៧២ មន្ទីរពេទ្យ ដំណើរការជា CPA៣ (៣៣ មន្ទីរពេទ្យ) និង CPA២ (៣៩ មន្ទីរពេទ្យ)។

## គោលបំណង ឬ សមាសធាតុទីបួនៈ ការពន្យារកំណើត

បង្កើនអត្រា នៃការប្រើប្រាស់មធ្យោបាយពន្យារកំណើត និងតម្រូវការ នៃការពន្យារកំណើតមានការពេញចិត្តចំពោះមធ្យោបាយទំនើប។

### សនិទាន

ខណៈពេលដែលតម្រូវការផែនការគ្រួសារដែលមិនបានបំពេញនៅទ្រឹងត្រឹមកម្រិត ១២% ចន្លោះឆ្នាំ ២០១៤ និង ២០២១-២២ អត្រាកំណើតក្នុងចំណោមមនុស្សវ័យជំទង់ធ្លាក់ចុះពី ៥៦ ទៅ ៤៨ ក្នុងស្ត្រី ១ ០០០ នាក់ដែលមានអាយុពី១៥-១៩ ឆ្នាំ ហើយតម្រូវការពន្យារកំណើតដែលមានការពេញចិត្តចំពោះមធ្យោបាយពន្យារកំណើតទំនើបក្នុងចំណោមស្ត្រីដែលបានរៀបការកំពុងកើនឡើងបន្តិចម្តងៗរហូតដល់បច្ចុប្បន្នមាន ៦១%។ ទោះជាយ៉ាងណាក៏ដោយ ការខិតខំប្រឹងប្រែងជាបន្តគឺចាំបាច់សម្រាប់ការធ្វើឱ្យប្រសើរឡើងបន្ថែមទៀតជាមួយនឹងយុទ្ធសាស្ត្រគោលដៅដើម្បីអាចទៅដល់ប្រជាជនដែលមិនទាន់ទទួលបានដើម្បីដោះស្រាយគម្លាតនេះ។ មណ្ឌលសុខភាពដែលដំណើរការទាំងអស់ មានបុគ្គលិកបានទទួលការបណ្តុះបណ្តាលអំពីការពន្យារកំណើត និងផ្តល់មធ្យោបាយពន្យារកំណើតរយៈពេលខ្លីយ៉ាងតិច ៣មធ្យោបាយ ។ ចំនួនមូលដ្ឋានសុខាភិបាលសាធារណៈដែលមានមធ្យោបាយពន្យារកំណើតរយៈពេលខ្លី និងរយៈពេលវែង ក៏បានកើនឡើងជាលំដាប់ផងដែរ ហើយមធ្យោបាយទាំងពីរនេះ ត្រូវបានផ្តល់ជូនដោយអង្គការមិនមែនរដ្ឋាភិបាល និងគ្លីនិកឯកជនផងដែរ។ ស្ត្រី ៤៦% នាពេលបច្ចុប្បន្ន ប្រើប្រាស់មធ្យោបាយទំនើបដែលទទួលបានពីមូលដ្ឋានសុខាភិបាលសាធារណៈ នៅខណៈពេលដែល ៥២% ទទួលបានពីវិស័យឯកជន។ កម្មវិធីទីផ្សារសង្គមបានចែកចាយមធ្យោបាយពន្យារកំណើតយ៉ាងសកម្មនៅទូទាំងប្រទេស។ ចាប់ពីឆ្នាំ២០១៦ រហូតដល់បច្ចុប្បន្ន មធ្យោបាយពន្យារកំណើតដែលផ្គត់ផ្គង់ដល់មូលដ្ឋានសុខាភិបាលសាធារណៈ ត្រូវបានទិញតាមរយៈអង្គការ UNFPA ដោយប្រើថវិការដ្ឋាភិបាល (ប្រហែល ២ លានដុល្លារអាមេរិកក្នុងមួយឆ្នាំ)។ ចំនួននេះត្រូវបានធានាសម្រាប់សេវាសាធារណៈ។ គ្លីនិកឯកជន និងឱសថស្ថានទទួលបានការផ្គត់ផ្គង់ពីផ្នែកទីផ្សារសង្គម។ វិធីសាស្ត្រទីផ្សាររួម ហាក់បីដូចជាដំណើរការបានល្អនៅក្នុងប្រទេសកម្ពុជា។ តម្រូវការសរុប នៃការពន្យារកំណើតតាមបែបទំនើប ដែលបានបំពេញ បានកើតឡើងពី ៥៦% នៅឆ្នាំ២០១៤ ទៅ ៦១% នៅឆ្នាំ២០២១-២២។ ទោះបីជាយ៉ាងណាក៏ដោយ ការប្រើប្រាស់មធ្យោបាយពន្យារកំណើត តាមបែបបុរាណនៅមានកម្រិតខ្ពស់។ ការប្រើប្រាស់មធ្យោបាយពន្យារកំណើតបែបទំនើបមានភាពខុសគ្នាទៅតាមកម្រិតវប្បធម៌ និងកំរិតជីវភាព ហើយកង្វល់នានាត្រូវបានលើកឡើងទាក់ទងនឹងគុណភាព នៃការកត់ត្រា និងរបាយការណ៍អតិថិជនកំពុងប្រើប្រាស់ អតិថិជនបោះបង់ នៅមូលដ្ឋានសុខាភិបាលសាធារណៈ។

FTIRM ផ្តោតលើការកែលម្អ និងការពង្រីកសេវាពន្យារកំណើត ជាពិសេសទៅកាន់តំបន់ដាច់ស្រយាល និងពិបាកទៅដល់ ការកែលម្អគុណភាព នៃការកត់ត្រា ការរក្សាទុក និងរបាយការណ៍ទិន្នន័យ ការធានាសុវត្ថិភាព នៃមធ្យោបាយពន្យារកំណើត និងបង្កើនលទ្ធភាពទទួលបានសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជរបស់យុវវ័យប្រកបដោយមិត្តភាព (AYFSRH)។

## អន្តរាគមន៍គន្លឹះ

### ១. បន្តពង្រីកការគ្របដណ្តប់ នៃសេវាពន្យារកំណើត

ក- បង្កើនចំនួនមូលដ្ឋានសុខាភិបាល ដែលផ្តល់សេវាពន្យារកំណើតប្រកបដោយគុណភាពរួមទាំងការពង្រឹងសមត្ថភាពរបស់អ្នកផ្តល់សេវាសុខភាពក្នុងការផ្តល់មធ្យោបាយពន្យារកំណើតរយៈពេលវែង (LARC) និងមធ្យោបាយអចិន្ត្រៃយ៍។

ខ- ពង្រឹងសមត្ថភាពអ្នកផ្តល់សេវាអំពីជំនាញទំនាក់ទំនង និងការផ្តល់ប្រឹក្សាពីមធ្យោបាយពន្យារកំណើត

គ- បង្កើនការទទួលបាននូវមធ្យោបាយអចិន្ត្រៃយ៍ (សម្រាប់បុរស និងស្ត្រី)

ង- បន្តការផ្តល់សេវាកម្មពីចម្ងាយ សម្រាប់ការធ្វើផែនការគ្រួសារ។

### ២. ពង្រឹងគុណភាព នៃសេវាពន្យារកំណើត

ក- ធ្វើការវាយតម្លៃរហ័ស និងរៀបចំផែនការបណ្តុះបណ្តាល ស្តីពីការពន្យារកំណើតកម្រិតមូលដ្ឋាន ដែលរួមមានការគ្រប់គ្រងសេវាពន្យារកំណើត (ការកត់ត្រា និងរបាយការណ៍ទិន្នន័យ ការគ្រប់គ្រងការផ្គត់ផ្គង់នៅមូលដ្ឋានសុខាភិបាលសាធារណៈសម្រាប់គ្រូពេទ្យ និងឆ្មប)។ ស្វែងរកឱកាសធ្វើសមាហរណកម្មទិន្នន័យសេវាពន្យារកំណើតក្រោយពេលរំលូតកូន និងការចុះឈ្មោះអតិថិជនក្រោយពេលរំលូតកូនជាអតិថិជនថ្មី

ខ- ពិនិត្យឡើងវិញឧបករណ៍វាយតម្លៃគុណភាព និងរួមបញ្ចូលការកត់ត្រា និងរបាយការណ៍ទិន្នន័យ នៃការពន្យារកំណើត និងធ្វើការវាយតម្លៃគុណភាពឬកែលម្អគុណភាពជាទៀងទាត់

គ- ធ្វើការតាមដានការបណ្តុះបណ្តាល ការបង្វឹក ដើម្បីពង្រឹងជំនាញផ្តល់ប្រឹក្សាគ្រប់មធ្យោបាយទាំងអស់រួមទាំងមធ្យោបាយរយៈពេលវែង និងការត្រួតពិនិត្យអ្នកផ្តល់សេវា។

### ៣. ធានាសុវត្ថិភាព នៃមធ្យោបាយពន្យារកំណើត

ក- ដំណើរការឡើងវិញនូវក្រុមការងារសុវត្ថិភាពមធ្យោបាយពន្យារកំណើត ដើម្បីធានាសុវត្ថិភាព នៃមធ្យោបាយពន្យារកំណើត

ខ- ធានាថាមានថវិកាប្រហែល ២ លានដុល្លារក្នុងមួយឆ្នាំ សម្រាប់ទិញមធ្យោបាយពន្យារកំណើតផ្គត់ផ្គង់មូលដ្ឋានសុខាភិបាលសាធារណៈ

គ- ឱ្យមានការចូលរួមរបស់ថ្នាក់ក្រោមជាតិ ដើម្បីកែលម្អការធ្វើផែនការ និងការគ្រប់គ្រងមធ្យោបាយពន្យារកំណើត (រួមទាំងការគ្រប់គ្រងស្តុក ការស្នើសុំការធ្វើបច្ចុប្បន្នភាព និងការរាយការណ៍ផងដែរ)។

### ៤. បង្កើនភាពអាចស្វែងរកបាន និងលទ្ធភាពទទួលបានសេវាកម្ម AYFSRH

ក- បន្តផ្តល់ការបណ្តុះបណ្តាលអំពីសេវាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជរបស់យុវវ័យប្រកបដោយមិត្តភាព (AYFSRH)

ខ- ពង្រីកសេវា AYFSRH ស្របតាមគោលការណ៍ណែនាំអំពី AYFSRH (រួមទាំង មានកន្លែងសុវត្ថិភាពផងដែរ)

គ- ភ្ជាប់ទំនាក់ទំនងរវាងសេវា AYFSRH និងកម្មវិធីសុខភាពសាលារៀន (កម្មវិធីនៅក្នុង និងនៅក្រៅសាលារៀន)។

## គោលបំណង ឬ សមាសធាតុទីប្រាំ៖ ការរំលូតកូនប្រកបដោយសុវត្ថិភាព

បង្កើនភាពអាចស្វែងរកបាន និងលទ្ធភាពទទួលបានសេវារំលូតកូនប្រកបដោយសុវត្ថិភាពរួមជាមួយការពន្យារកំណើតក្រោយរំលូត។

### សនិទាន

ការបណ្តុះបណ្តាលអំពីការថែទាំការរំលូតកូនប្រកបដោយសុវត្ថិភាព (CAC) ត្រូវបានអនុវត្តចាប់តាំងពីឆ្នាំ២០០៧ នៅមូលដ្ឋានសុខាភិបាលសាធារណៈដែលមានលក្ខខណ្ឌសមស្រប មានបុគ្គលិកមានលក្ខខណ្ឌសមស្រប នឹងទទួលបានការបណ្តុះបណ្តាលស្របតាមច្បាប់រំលូតកូន នៃប្រទេសកម្ពុជា។ ចាប់ពីឆ្នាំ២០១៦ ដល់ ឆ្នាំ២០២២ មូលដ្ឋានមួយចំនួនមានបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលអំពី CAC ហើយការផ្តល់សេវាកម្ម បានកើនឡើងពី ៦៤៩ ទៅ ៧៩៣មូលដ្ឋានសុខាភិបាល (៥២,៦% នៃមូលដ្ឋានសុខាភិបាលសរុប)។ CAC ក៏ត្រូវបានផ្តល់ជូននៅតាមមូលដ្ឋានរបស់អង្គការមិនមែនរដ្ឋាភិបាលផងដែរ ជាពិសេស អង្គការម៉ារីស្តូបអន្តរជាតិកម្ពុជា (MSIC) និងគ្លីនិករ៉ាក់។ ការបណ្តុះបណ្តាលអំពីការរំលូតកូនដោយប្រើឱសថ (MA) ក៏ត្រូវបានអនុវត្តនៅក្នុងប្រទេសផងដែរ ហើយមកទល់ឆ្នាំ២០២២ មូលដ្ឋានសុខាភិបាលដែលផ្តល់សេវា MA បានកើនឡើងដល់ ៤៤៨ មូលដ្ឋានសុខាភិបាលសាធារណៈ។ ជាលទ្ធផល CDHS បានបង្ហាញថាអត្រារំលូតកូនបានថយចុះពី ១២% ក្នុងឆ្នាំ២០១៤ មកត្រឹម ៩% ក្នុងឆ្នាំ ២០២១-២២។ ទោះបីជាយ៉ាងណាក៏ដោយពុំមានទិន្នន័យអំពីការរំលូតកូនច្រើនដងឬម្តងហើយម្តងទៀតនោះទេ។

FTIRM ២០២៥-២០៣០ ផ្តោតលើការបង្កើនចំនួនមូលដ្ឋានសុខាភិបាលដែលមានលក្ខខណ្ឌសមស្របក្នុងការផ្តល់សេវាកម្ម CAC ពង្រឹងសេវាកម្មប្រកបដោយគុណភាព និងរួមបញ្ចូលការធ្វើផែនការគ្រួសារក្រោយពេលរំលូតកូន។

## អន្តរាគមន៍គន្លឹះ

### ១. បង្កើនលទ្ធភាពទទួលបាន និងពង្រឹងគុណភាព នៃសេវារំលូតកូនប្រកបដោយសុវត្ថិភាព

ក- ធ្វើការវាយតម្លៃអំពីតម្រូវការ នៃការបណ្តុះបណ្តាល CAC និងបង្កើតផែនការបណ្តុះបណ្តាល

ខ- បង្កើនទំនាក់ទំនងរវាងសេវា CAC និងសេវាពន្យារកំណើតជាទម្លាប់ នៅមូលដ្ឋានសុខាភិបាល ដើម្បីធានាថាអតិថិជនដែលរំលូតកូនរួចគ្រប់រូបមានលទ្ធភាពទទួលបានសេវាពន្យារកំណើត និងជៀសវាងការរំលូតកូនច្រើនដងឬម្តងហើយម្តងទៀត

គ- ស្វែងរកមតិគាំទ្រដើម្បីកៀរគរធនធានបន្ថែម សម្រាប់ការថែទាំការរំលូតកូនដោយសុវត្ថិភាព រួមទាំងការបណ្តុះបណ្តាល ការផ្តល់ឧបករណ៍ និងឱសថរំលូតកូនដល់មូលដ្ឋានសុខាភិបាលសាធារណៈ

ឃ- ធ្វើការបណ្តុះបណ្តាល ស្តីពីការរំលូតកូនប្រកបដោយសុវត្ថិភាព ការថែទាំក្រោយរំលូត ការរំលូតកូនដោយប្រើឱសថការពន្យារកំណើតក្រោយរំលូតកូនសម្រាប់មូលដ្ឋានសុខាភិបាលសាធារណៈ ដែលមានលក្ខខណ្ឌសមស្រប។ រាល់ការបណ្តុះបណ្តាលទាំងអស់គួរតែរួមបញ្ចូលវគ្គ ស្តីពីការកាត់បន្ថយការមាក់ងាយដែលទាក់ទង នឹងការរំលូតកូន ឬកង្វះចំណេះដឹងឬព័ត៌មានមិនពិតអំពីការថែទាំការរំលូតកូនប្រកបដោយសុវត្ថិភាព ដូចជា " ការបញ្ជាក់អំពីគុណតម្លៃ និងការផ្លាស់ប្តូរអាកប្បកិរិយា (VCAT)" ជាដើម

ង- ប្រសិនបើអាចធ្វើបាន ធ្វើការបណ្តុះបណ្តាលសម្រាប់សេវាឯកជន ដែលមានលក្ខខណ្ឌសមស្រប

ច- រួមបញ្ចូលគ្រប់ភាគីពាក់ព័ន្ធ ដើម្បីធានាឱ្យបាននូវការអនុវត្តច្បាប់រំលូតកូន និងការសង្គ្រោះជីវិតស្ត្រី

ឆ- ធានាបាននូវការត្រួតពិនិត្យជាប្រចាំ និងយ៉ាងម៉ឺងម៉ាត់ និងផ្តល់ការបង្វឹកដល់មូលដ្ឋានដែលផ្តល់សេវារំលូតកូន

ជ- ធ្វើការវាយតម្លៃគុណភាពនៅមូលដ្ឋានសុខាភិបាល ដែលផ្តល់សេវា CAC។

### ២. កាត់បន្ថយការរំលូតកូនច្រើនដង/ម្តងហើយម្តងទៀត

ក- អនុវត្តការផ្តល់សេវាព្យាបាលពីចម្ងាយ លើការថែទាំក្រោយពេលរំលូតកូន ពង្រឹងជំនាញពិគ្រោះពិភាក្សាអំពីការពន្យារកំណើត

ខ- ធ្វើការវិភាគទិន្នន័យបន្ទាប់បន្សំ (secondary analysis) ស្តីពីការរំលូតកូន ដើម្បីទទួលបានអត្រាប្រេវ៉ាឡង់នៃការរំលូតកូនច្រើនដង និងសមាមាត្រ នៃការរំលូតកូនច្រើនដងទៅតាមតំបន់ឬទីកន្លែង កម្រិតវប្បធម៌ និងកម្រិតជីវភាព និងកំណត់គោលដៅសម្រាប់ឆ្នាំ២០៣០

គ- ធ្វើការសិក្សាស្រាវជ្រាវទាក់ទងនឹងការរំលូតកូន។

## គោលបំណង ឬ សមាសធាតុទីប្រាំមួយៈ លុបបំបាត់ឧបសគ្គផ្នែកហិរញ្ញវត្ថុក្នុងការទទួលបានសេវាថែទាំសុខភាព ឆ្ពោះទៅសម្រេចបានគ្របដណ្តប់សេវាសុខាភិបាលជាសកល (UHC)

បង្កើនសមាមាត្រ នៃស្ត្រីក្នុងវ័យបន្តពូជ (និងសមាមាត្រ នៃទារកទើបនឹងកើត) ដែលគ្របដណ្តប់ដោយប្រព័ន្ធគាំពារសុខភាពសង្គម (មូលនិធិសមធម៌សុខភាព និង ប.ស.ស)

### សនិទាន

រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញាចិត្តសម្រេចឱ្យបាននូវការគ្របដណ្តប់សុខភាពជាសកល (UHC) សម្រាប់ប្រជាជនរបស់ខ្លួន ដែលធានាថា ប្រជាជនគ្រប់រូបទទួលបានសេវាសុខភាពដែលពួកគេត្រូវការ ដោយពុំមានហានិភ័យហិរញ្ញវត្ថុនៅពេលទូទាត់សេវាសុខាភិបាល។ ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦-២០២៥ បានចាប់ផ្តើមដំណើរការនៅខែមីនា ឆ្នាំ ២០១៧ ដែលបែងចែកជាជំនួយសង្គម និងសន្តិសុខសង្គម។ ការពិនិត្យវឌ្ឍនភាពនៃ FTIRM ២០១៦-២០២០ មានការរីកចម្រើនក្នុងការគ្របដណ្តប់ នៃមូលនិធិសមធម៌សុខាភិបាល និងកម្មវិធីអាហារូបត្ថម្ភសម្រាប់ស្ត្រីផ្ទៃពោះ និងកុមារដែលជាផ្នែក នៃកម្មវិធីជំនួយសង្គម និងពិនិត្យលើស្ត្រីដែលបានចុះឈ្មោះក្រោមបេឡាជាតិរបបសន្តិសុខសង្គម និងបេឡាជាតិរបបសន្តិសុខសង្គមដែលជាផ្នែកមួយ នៃរបបសន្តិសុខសង្គម។ ជាលទ្ធផលការអង្កេតប្រជាសាស្ត្រ និងសុខភាពនៅឆ្នាំ២០២២ បានបង្ហាញថា ភាគរយ នៃស្ត្រីក្នុងវ័យបន្តពូជ (១៥-៤៩) ដែលមានទម្រង់ណាមួយ នៃធានារ៉ាប់រងសុខភាពបានកើតឡើងពី ១៦% នៅឆ្នាំ២០១៤ ទៅ ២១,៧% នៅឆ្នាំ២០២១-២២។ នៅក្នុងខែមីនា ឆ្នាំ ២០២៤ របាយការណ៍ "សមិទ្ធិផលក្នុងវិស័យ បានបង្ហាញថា ការគ្របដណ្តប់ប្រជាជនក្រោមរបបសន្តិសុខសង្គមបានកើនឡើងពី ៣៦,៩% (២០២២) ដល់ ៤៩,៤% (២០២៣)[16] ។ របាយការណ៍នេះក៏បានបញ្ជាក់ផងដែរថា ស្ត្រីមានផ្ទៃពោះចំនួន ៤១ ៣៣២ នាក់ (១២,៤%[17]

[16] The Achievement in Health Sector 2023, MoH March 2024.

[17] Expected pregnant women in 2023 equal 333153.

នៃស្ត្រីមានផ្ទៃពោះដែលរំពឹងទុក) បានសម្រាលកូននៅក្នុងមូលដ្ឋានសុខាភិបាលសាធារណៈដែលគាំទ្រដោយ HEF ។ ក្នុងពេលជាមួយគ្នានេះ ស្ត្រីមានផ្ទៃពោះចំនួន ៧៥ ០២២នាក់ សម្រាលនៅមូលដ្ឋានសុខាភិបាលដែលគាំទ្រដោយមូលនិធិជាតិគាំពារសង្គម[18] ។

FTIRM ២០២៥-២០៣០ ផ្តោតលើការទទួលបានសេវាសុខភាពបន្តពូជ សុខភាពមាតា និងទារកទើបនឹងកើតជាសកល សម្រាប់ស្ត្រីក្នុងវ័យបន្តពូជ និងទារកទើបនឹងកើត។

### អន្តរាគមន៍គន្លឹះ:

**ធានាថា ស្ត្រីក្នុងវ័យបន្តពូជ និងទារកទើបនឹងកើតគ្រប់រូបបានចុះឈ្មោះនៅក្រោមរបបគាំពារសង្គម**

- បន្តអនុវត្តក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦-២០២៥
- អនុវត្តផែនទីបង្ហាញផ្លូវឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជា ២០២៤-២០៣៥
- ធ្វើការសិក្សាឬវិភាគបន្ថែម ដើម្បីស្វែងយល់ពីស្ត្រីក្នុងវ័យបន្តពូជ និងទារកទើបនឹងកើត ដែលគ្របដណ្តប់ដោយរបបបេឡាជាតិគាំពារសង្គម។

## គោលបំណង ឬ សមាសធាតុទីប្រាំពីរ៖ ការចូលរួមរបស់បុគ្គល គ្រួសារ និងសហគមន៍ ដើម្បីកែលម្អសុខភាពស្ត្រី និងទារកទើបនឹងកើត

ការថែទាំសុខភាពបឋមគឺជាគន្លងដើម្បីជំរុញការចូលរួមរបស់បុគ្គល គ្រួសារ និងសហគមន៍ នៅក្នុងការលើកកម្ពស់ និងពង្រឹងសុខភាពស្ត្រី និងទារកទើបនឹងកើត។

### សនិទាន

ប្រទេសកម្ពុជាបាន និងកំពុងឆ្លងកាត់ដំណើរការវិមជ្ឈការ ដោយអំណាចកាន់តែច្រើនត្រូវបានផ្ទេរទៅឱ្យអាជ្ញាធរថ្នាក់ក្រោមជាតិ និងអាជ្ញាធរមូលដ្ឋានជាបន្តបន្ទាប់ ដើម្បីសម្រេចគោលដៅ នៃតម្រូវការរបស់សហគមន៍ និងអនុវត្តយុទ្ធសាស្ត្រ និងគោលនយោបាយជាតិ។ វាមានសារៈសំខាន់ណាស់ក្នុងការទទួលស្គាល់ថា សុខភាពមិនអាចប្រសើរឡើងបានតាមរយៈអន្តរាគមន៍របស់អ្នកជំនាញផ្នែកសុខភាព និងបុគ្គលិកសុខាភិបាលតែមួយមុខនោះទេ។ បុគ្គល គ្រួសារ សហគមន៍ អាជ្ញាធរមូលដ្ឋាន និងភាគីពាក់ព័ន្ធដទៃទៀត មានសារៈសំខាន់ស្មើៗគ្នាក្នុងដោះស្រាយកត្តាសង្គមដែលកំណត់សុខភាព និងជាពិសេស ការលើកកម្ពស់សុខភាពមាតា និងទារក និងកាត់បន្ថយមរណភាពមាតា និងទារក។ SDH គឺជាកត្តាសំខាន់លើសពីការថែទាំសុខភាពដែលមានឥទ្ធិពលលើលទ្ធផលសុខភាព ដែលរួមមានការអប់រំ លំនៅដ្ឋាន បរិយាកាសរស់នៅ ការគាំទ្រសង្គម ប្រាក់ចំណូលគ្រួសារ ការងារ និងកត្តាផ្សេងទៀតលើសពីអ្វីដែលការថែទាំសុខភាពអាចផ្តល់ឱ្យ។ នេះមានន័យថា កិច្ចសហការពហុវិស័យក្រោមការដឹកនាំរបស់រដ្ឋបាលមូលដ្ឋានក្លាយជាកត្តាសំខាន់។

---

[18] Report from National Social Protection in Cambodia. NSPC August 2024.

FTIRM ២០២៥-២០៣០ ស្របនឹងក្របខ័ណ្ឌអនុវត្តការជំរុញបង្កើនការងារថែទាំសុខភាពបឋម (PHC-BIF) ដោយផ្តល់អំណាចដល់បុគ្គល គ្រួសារ និងសហគមន៍ និងបង្កើនគណនេយ្យភាពរបស់សហគមន៍ និងការដឹកនាំរបស់អាជ្ញាធរមូលដ្ឋានក្នុងការកែលម្អសុខភាពសហគមន៍ រួមទាំងសុខភាពមាតា និងទារក។ វាក៏សង្កត់ធ្ងន់ផងដែរអំពីសារៈសំខាន់នៃអ្នកផ្តល់សេវាថែទាំសុខភាព និងប្រព័ន្ធសុខភាពដែលទទួលបានការជឿទុកចិត្តពីសហគមន៍។

## អន្តរាគមន៍គន្លឹះ

### ១. ជំរុញគណនេយ្យភាពរបស់សហគមន៍ចំពោះសុខភាពមាតា និងទារក កាត់បន្ថយភាពយឺតយ៉ាវក្នុងការស្វែងរកការថែទាំ និងលើកកម្ពស់លទ្ធផលវិជ្ជមាននៃការមានផ្ទៃពោះ

ក- បង្កើតវិធីសាស្ត្រ និងឧបករណ៍ដើម្បី៖ (1) ស្វែងយល់ពីទស្សនៈ និងកាលៈទេសៈ នៃអាកប្បកិរិយា និងស្វែងរកការថែទាំរបស់សហគមន៍ (2) គាំទ្រការធ្វើផែនការដោយមានការចូលរួមកម្រិតសហគមន៍ ដោយកំណត់រកធនធាននៅមូលដ្ឋាន និងឱកាសសម្រាប់ការកែលម្អ MNH ។

ខ- ការចូលរួមយ៉ាងសកម្មពីក្រុមប្រជាជនដែលមិនពិបាកទៅដល់ រួមមានកម្មកររោងចក្រ អ្នកបម្រើសេវាកម្សាន្តជនជាតិភាគតិច ជនចំណាកស្រុក ជនពិការ (ក្មេងជំទង់ និងមនុស្សពេញវ័យ) សិស្សានុសិស្សយុវជនដែលបោះបង់ការសិក្សា ក្រុម LGTBQI ដើម្បីឱ្យពួកគាត់ទទួលខុសត្រូវចំពោះសុខភាពផ្ទាល់ខ្លួន និងអាចស្វែងរកសេវាសុខភាពសមស្រប។

គ- ការចូលរួមអ្នកដឹកនាំសហគមន៍ អ្នកមានឥទ្ធិពល និងអ្នកជំនាញផ្នែកថែទាំសុខភាព ដើម្បីផ្សព្វផ្សាយព័ត៌មានផ្អែកលើភស្តុតាង ដែលលុបបំបាត់ជំនឿមិនពិត និងផ្តល់ព័ត៌មានជាក់ស្តែងអំពីសុវត្ថិភាព និងច្បាប់នៃការរំលូកូន។

ឃ- ការចូលរួមពីគ្រូបង្រៀននៅសាលា ដើម្បីធានាថាកុមារមានឱកាសទទួលបានព័ត៌មានពីសុខភាពបន្តពូជត្រឹមត្រូវជាផ្នែក នៃការអប់រំផ្លូវភេទដ៏ទូលំទូលាយ ជួយពួកគេឱ្យការពារខ្លួន និងធ្វើការសម្រេចចិត្តដោយផ្អែកលើព័ត៌មាន។ ពង្រឹងភាពជាអ្នកដឹកនាំក្នុងមូលដ្ឋាន រួមទាំងការវិនិយោគបន្ថែមទៀតនៅក្នុងផែនការវិនិយោគឃុំឬសង្កាត់ និង ប្រមូលផ្តុំសកម្មភាពពហុវិស័យសម្រាប់ការកែលម្អសុខភាពស្ត្រីនិងទារកទើបនឹងកើត។

### ២. គាំទ្រការផ្តល់សេវាសុខភាពប្រកបដោយគុណភាព

ក- អភិវឌ្ឍសមត្ថភាពរបស់អ្នកផ្តល់សេវាថែទាំសុខភាពលើជំនាញទំនាក់ទំនងប្រកបដោយការគោរព និងមិនប្រកាន់ឋានានុក្រម ដើម្បីបង្កើតទំនាក់ទំនងគួរឱ្យទុកចិត្តនៅក្នុងសហគមន៍ ដើម្បីលើកកម្ពស់លទ្ធផលវិជ្ជមាន នៃការមានផ្ទៃពោះ។

ខ- ការចូលរួមរបស់សហគមន៍ (អាជ្ញាធរមូលដ្ឋាន VHSG អង្គការមិនមែនរដ្ឋាភិបាល) និងអ្នកប្រើប្រាស់សេវាសុខាភិបាល ក្នុងការផ្តល់មតិកែលម្អ

គ- ពង្រឹងភាពជាដៃគូរវាងវិស័យឯកជន និងសាធារណៈ រួមទាំងអង្គការមិនមែនរដ្ឋាភិបាល មូលដ្ឋានឯកជនដើម្បីលើកកម្ពស់គុណភាពសេវាមាតា និងទារក និងការចូលរួមវិស័យឯកជនក្នុងផែនការសុខភាពសាធារណៈ និងការផ្តល់សេវានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ឃ- ពង្រឹងការអនុវត្តច្បាប់ឬប្រកាស ស្តីពីការរំលូតកូន

# ក្របខ័ណ្ឌតាមដាន និងវាយតម្លៃ

| សូចនាករ | ទិន្នន័យមូលដ្ឋាន CDHS ឆ្នាំ២០២២ | គោលដៅ ឆ្នាំ ២០៣០ | គោលដៅ សកល |
|---|---|---|---|
| **គោលដៅ** | | | |
| អត្រាមរណភាពមាតា (ក្នុង ១០០ ០០០ កំណើតរស់) | ១៥៤ | ៧០[19] | ៧០ |
| អត្រាមរណភាពទារក (ក្នុង ១ ០០០ កំណើតរស់) | ៨ | < ៨ | ១២ |
| **គោលបំណងឬសមាសធាតុស្នូលទី១៖ ការសម្រាលដោយឆ្មបជំនាញ** | | | |
| ភាគរយ នៃមណ្ឌលសុខភាពដែលមានឆ្មបមធ្យមយ៉ាងតិច ២ រូប (ADM) (%) | ៨៣[20] | ≥ ៩៨ | - |
| ភាគរយ នៃស្ត្រីដែលបានទទួលការពិនិត្យផ្ទៃពោះយ៉ាងតិច៤ ដង(%) | ៨៦,៣ | ៩០ | ៩០ (EPMM) |
| ភាគរយ នៃការសម្រាលកូននៅមូលដ្ឋានសុខាភិបាល (%) | ៩៨ | ៩៩ | ៩០ (EPMM) |
| ភាគរយ នៃការថែទាំក្រោយសម្រាល (PNCALL[21]) ក្នុងរយៈពេល ២ ថ្ងៃ បន្ទាប់ពីកំណើត (%) | ៧៤,២ | ≥ ៩៥ | ៩០ (EPNDS) |
| ភាគរយ នៃស្ត្រីបានទទួលការថែទាំក្រោយសម្រាលលើកទី ១ PNC ១ (សេវាសាធារណៈ) ក្នុងរយៈពេល ៧ថ្ងៃ បន្ទាប់ពីកំណើត (%) | ៥៤,៥[22] | ៨៥ | - |
| **គោលបំណងឬសមាសធាតុស្នូលទី២៖ សេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងការថែទាំទារកទើបនឹងកើត** | | | |
| ការគ្របដណ្តប់ នៃសេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងការថែទាំទារកទើបនឹងកើត មូលដ្ឋាន BEmONC | BEmONC មាន ៤៥ ១,៤៨[23] (ដំណើរការ) | BEmONC ≥ ១៤៤ | ៤ សម្រាប់ប្រជាជន ៥០០ ០០០ នាក់ |
| ការគ្របដណ្តប់ នៃសេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភព និងការថែទាំទារកទើបនឹងកើតពេញលេញ CEmONC | CEmONC ចំនួន ៣៥ ១,១៤[24] (ដំណើរការ) | CEmONC ≥ ៣៦ | ១ សម្រាប់ប្រជាជន ៥០០ ០០០ |

[19] CSDG ឆ្នាំ២០១៦-២០៣០. បញ្ជីគោលដៅដែលត្រូវបានកែសម្រួល និងសូចនាករតាមគោលដៅ ខែកក្កដា ឆ្នាំ២០២២។ MoP
[20] របាយការណ៍សន្និបាទវិស័យសុខាភិបាល ឆ្នាំ២០១៨-២០២២។ MoH
[21] PNCALL = PNC សម្រាប់ម្តាយ និងទារក
[22] របាយការណ៍សន្និបាទសុខាភិបាល ឆ្នាំ២០១៨-២០២២។ MoH
[23] ការពិនិត្យឡើងវិញផែនការកែលម្អ EmONC ឆ្នាំ២០២០
[24] ការពិនិត្យឡើងវិញផែនការកែលម្អ EmONC ឆ្នាំ២០២០

| | | | |
|---|---|---|---|
| មូលដ្ឋានសុខាភិបាល EmONC មានប្រជាជនដែលរស់នៅធ្វើដំណើរលើសពី ២ ម៉ោង ពីមូលដ្ឋានសុខាភិបាល (%) | ៣៤,៨[25]<br>(៦៣/១៨១) | ១០<br>(១៨/១៨១) | - |
| ការសម្រាលដោយវះកាត់ (%) នៅថ្នាក់ជាតិ (បែងចែកជាសេវាសាធារណៈ និងឯកជន) និងនៅថ្នាក់ក្រោមជាតិ | ១៧,៩<br>សាធារណៈ៖ ១០,៣<br>ឯកជន៖ ៥០,២<br>ភ្នំពេញ៖ ២៩,១<br>ត្បូងឃ្មុំ៖ ២៦,៦<br>កណ្ដាល៖ ២៤,៥<br>កំពត៖ ២៤,៣<br>ក្រចេះ៖ ៦,៣<br>កំពង់ធំ៖ ៦,៧<br>រតនគិរី៖ ២,០ | ១៧<br>ពុំមានខេត្តណាមួយលើស ១៧%<br>និងពុំមានខេត្តណាមួយក្រោម ១០%<br>នោះទេ | - |
| **គោលបំណងឬសមាសធាតុស្នូលទី៣៖ ការថែទាំទារកទើបនឹងកើត** | | | |
| សមាមាត្រទារកដែលត្រូវបានបំបៅដោយទឹកដោះម្ដាយក្នុងរយៈពេល១ម៉ោងក្រោយពេលកើត (%) | ៥៣,៨ | ៨០ | - |
| សមាមាត្រទារកបានទទួលការបំបៅកូនដោយទឹកដោះម្ដាយតែមួយមុខគត់មុនពេលចេញពីមូលដ្ឋានសុខាភិបាល (%) | ៥៧,៧[26] | > ៨០ | - |
| សមាមាត្រ នៃការដាក់ទារកទើបនឹងកើតនៅលើទ្រូងម្ដាយក្នុងរយៈពេល ៩០ នាទី (%) | ៦៦,១[27] | > ៨០ | - |
| ចំនួនមូលដ្ឋានសុខាភិបាលដែលអនុវត្តកញ្ចប់ EENC | ២៩[28] | ៧០[29] | - |
| សមាមាត្រ នៃបុគ្គលិកនៅក្នុងមូលដ្ឋានសុខាភិបាលដែលអនុវត្ត EENC ដែលបានទទួលការបណ្ដុះបណ្ដាលអំពី INC,KMC,BF និងការឆ្លងមេរោគក្នុងឈាមទារក (%) | INC៖ ៣៣,៨[30]<br>(៤៧៣/១៤០០)<br>KMC៖ ១២,៩[31]<br>(១៨១/១៤០០) | ៨៥<br><br>៥០<br><br>>៨០ | - |

[25] ការពិនិត្យឡើងវិញផែនការកែលម្អ EmONC ឆ្នាំ២០២០.

[26] របាយការណ៍ HMIS ឆ្នាំ២០២២៖ ចំនួនទារកដែលបៅដោះម្ដាយតែមួយមុខគត់ ក្នុងអំឡុងពេលស្នាក់នៅក្នុងមូលដ្ឋានសុខាភិបាល ស្មើនឹង ១៥២.៧៥៣ នាក់ និងចំនួនកំណើតរស់ស្មើនឹង ២៦៤.៧៨៤

[27] របាយការណ៍ HMIS ឆ្នាំ២០២២៖ ចំនួនទារកទើបនឹងកើត ដែលត្រូវបានដាក់នៅលើខ្លួនម្ដាយក្នុងរយៈពេល ៩០ នាទី ស្មើនឹង ១៧៤.៩៥៩ ស្មើនឹង ២៦៤.៧៨៤ កំណើតរស់

[28] NPH NMCHC មន្ទីរពេទ្យនៅ ២៥ ខេត្ត មន្ទីរពេទ្យនៅមោងឫស្សី និង សំពៅលូន

[29] មន្ទីរពេទ្យ CPA៣ និង CPA ទាំងអស់ = ៧០ ទីតាំង។ ទីតាំងនីមួយៗមានបុគ្គលិក ២០ នាក់ ដែលបានទទួលបានការបណ្ដុះបណ្ដាលអំពី EENC.

[30] ផ្នែកបណ្ដុះបណ្ដាល / ទិន្នន័យ NMCHC

[31] ទិន្នន័យ NRHP

| | | | |
|---|---|---|---|
| | BF៖ ៩,៤[32] (១៣១/១៤០០) ការឆ្លងមេរោគក្នុងឈាមទារក៖ ៤,៣[33] (៦០/១៤០០) | ៣០ | |
| សមាមាត្រ នៃមន្ទីរពេទ្យ CPA៣ និង CPA២ ដែលមាន NCU[34] កម្រិត ២ សម្រាប់ទារកតូច និងមានជំងឺ (%) (KMC CPAP ការបំបៅដោយមានជំនួយ និងការបញ្ចូលសេរ៉ូមតាមសរសៃ ការគ្រប់គ្រងការឆ្លងរោគក្នុងឈាមទារកទើបនឹងកើត ជំងឺខាន់លឿង ជំងឺរលាកខួរក្បាល ការរកឃើញ ឬការបញ្ជូនភាពមិនប្រក្រតីពីកំណើត ការតាមដានទារកទើបនឹងកើតដែលមានហានិភ័យ ការព្យាបាលដោយការប្តូរឈាម) | ៤១,៧[35] (៣០/៧២) | ៧០ | ៨០%[36] នៃចំនួនស្រុក មានផ្នែកអ្នកជំងឺសម្រាកពេទ្យកម្រិត ២ យ៉ាងតិចមួយ ដើម្បីថែទាំទារកតូច និងមានជំងឺ ដោយ CPAP |
| **គោលបំណងឬសមាសធាតុស្នូលទី៤៖ ការពន្យារកំណើត** | | | |
| អត្រាប្រេវ៉ាឡង់ នៃការប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើប (%) | ៤៥ | ៦០ | - |
| ភាគរយនៃ ស្ត្រីដែលត្រូវការពន្យារកំណើតមានការពេញចិត្តចំពោះមធ្យោបាយពន្យារកំណើតទំនើប (%) | ៦០,៦ | ៦៨[37] | - |
| តម្រូវការផែនការគ្រួសារដែលមិនបានបំពេញ (%) | ១១,៨ | ៨ | មិនមាន (សូន្យ) តម្រូវការ FP ដែលមិនបានបំពេញ |
| ចំនួនមូលដ្ឋានសុខាភិបាលសាធារណៈដែលផ្តល់មធ្យោបាយពន្យារកំណើតតាមបែបទំនើបយ៉ាងតិច ៣<br>ចំនួនមូលដ្ឋានសុខាភិបាលសាធារណៈដែលផ្តល់ជូននូវវិធីសាស្ត្រពន្យារកំណើតអចិន្ត្រៃយ៍ | ១២០៥[38]<br>៣៤ | ១២៤០<br>៤០ | - |

[32] ទិន្នន័យ BFHI

[33] ទិន្នន័យរបស់មន្ទីរពេទ្យកុមារជាតិ

[34] គោលការណ៍ណែនាំអំពីសំណុំសកម្មភាពបង្គ្រប់ដើម្បីអភិវឌ្ឍន៍មន្ទីរពេទ្យបង្អែក ខែមិថុនា ឆ្នាំ២០១៤. MoH.

[35] NPH NMCHC មន្ទីរពេទ្យកាល់ម៉ែត្រ មន្ទីរពេទ្យខ្មែរ-សូវៀត មន្ទីរពេទ្យខេត្តចំនួន ២៤ មន្ទីរពេទ្យសំពៅលូន និង មន្ទីរពេទ្យមោងឬស្សី មាន NCU។ នៅឆ្នាំ២០២២ ប្រទេសកម្ពុជាមាន ៧២ មន្ទីរពេទ្យ ដែលផ្តល់ CPA៣ និង CPA២ (៣៣ CPA៣ និង ៣៩ CPA២).

[36] ការបញ្ឈប់មរណភាពទារកទើបនឹងកើត និងទារកកើតស្លាប់ ដែលអាចទប់ស្កាត់បាន ត្រឹមឆ្នាំ២០៣០. WHO និង Unicef.

[37] CSDG ឆ្នាំ២០១៦-២០៣០. បញ្ជីគោលដៅដែលត្រូវបានកែសម្រួល និងសូចនាករតាមគោលដៅ ខែកក្កដា ឆ្នាំ២០២២. MoP

[38] កម្មវិធីជាតិសុខភាពបន្តពូជ/NMCHC

| | | | |
|---|---|---|---|
| ចំនួនមូលដ្ឋានសុខាភិបាលសាធារណៈ ដែលមានសេវា AYFSRH | ១០០ | ១៥០ | - |
| **គោលបំណងឬសមាសធាតុស្នូលទី៥៖ ការរំលូតកូនដោយសុវត្ថិភាព** | | | |
| អត្រារំលូតកូន (%) | ៨,៨ | ៧ | - |
| ចំនួនមូលដ្ឋានសុខាភិបាលសាធារណៈដែលផ្តល់សេវារំលូតកូនដោយសុវត្ថិភាព | ៧៩៣[39] | ១០០០ | - |
| **គោលបំណងឬសមាសធាតុគាំទ្រទី៦៖ ការដកចេញនូវរបាំងហិរញ្ញវត្ថុដើម្បីឆ្ពោះទៅសម្រេចបាននូវការគ្របដណ្តប់សេវាសុខភាពជាសកល** | | | |
| ការគ្របដណ្តប់ប្រជាជនដោយប្រព័ន្ធគាំពារសុខភាពសង្គម (%)[40] | ៤៥ (២០២៤) | ៧០ | |
| ភាគរយ នៃស្ត្រីសម្រាលកូន ដែលគាំទ្រដោយ HEF នៅមូលដ្ឋានសុខាភិបាលសាធារណៈ (%) | ១២,៤[41] (៤១៣៣២/ ៣៣៣១៥៣) | TBC | |
| ភាគរយ នៃស្ត្រីសម្រាលកូនដែលគាំទ្រដោយ NSPF នៅមូល នៅមូលដ្ឋានសុខាភិបាល (%) | ២២,៥%[42] (៧៥០២២/ ៣៣៣១៥៣) | TBC | - |
| ភាគរយ នៃស្ត្រីក្នុងវ័យបន្តពូជ (១៥-៤៩) ដែលមានការធានារ៉ាប់រងសុខភាពណាមួយ (%)៖<br>• សន្តិសុខសង្គម<br>• ធានារ៉ាប់រងសុខភាពដទៃទៀតនៅកន្លែងធ្វើការ<br>• អង្គការសុខភាព/ការធានារ៉ាប់រងនៅក្នុងសហគមន៍ (CBHI )<br>• ការទិញធានាធានារ៉ាប់រងពីក្រុមហ៊ុន | ២១,៧ (CDHS 2021-22)<br>• ១៦,៤<br>• ០,៩<br>• ២,៤<br>• ២,២ | TBD (CDHS) | - |
| **គោលបំណងឬសមាសធាតុគាំទ្រទី៧៖ ការចូលរួមរបស់បុគ្គល គ្រួសារ និងសហគមន៍ ដើម្បីកែលម្អសុខភាពស្ត្រី និងទារកទើបនឹងកើត** | | | |

[39] កម្មវិធីជាតិសុខភាពបន្តពូជ/NMCHC

[40] ផែនទីបង្ហាញផ្លូវឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសកលនៅកម្ពុជាឆ្នាំ ២០២៤-២០៣៥

[41] The Achievement in Health Sector 2023. Estimated number of expected pregnant women was 333153.

[42] 75022 women delivered at health facility in 2023 (supported by NSPC).

| | | | |
|---|---|---|---|
| មណ្ឌលសុខភាពដែលមានគណៈកម្មការទ្រទ្រង់មណ្ឌលសុខភាពដំណើរការ (%) | ៨៧,៨[43] | ៩៥ | - |
| អត្រានៃការមានផ្ទៃពោះនៅវ័យជំទង់ (%) អត្រាសម្រាលកូនក្នុងចំណោមយុវវ័យអាយុ ១៥-១៩ ឆ្នាំ ១ ០០០ នាក់ | ៩,៣<br>៤៨ | ៤[44]<br>៤០ | - |

[43] របាយការណ៍សន្និបាទសុខាភិបាល ឆ្នាំ២០១៨-២០២២

[44] CSDG ឆ្នាំ២០១៦-២០៣០. បញ្ជីគោលដៅដែលត្រូវបានកែសម្រួល និងសូចនាករតាមគោលដៅ ខែកក្កដា ឆ្នាំ២០២២. MoP

## ឧបសម្ព័ន្ធទី១៖ ឯកសារយោង


1- ការពិនិត្យឡើងវិញផែនទីបង្ហាញផ្លូវសម្រាប់ពន្លឿនការកាត់បន្ថយអត្រាមរណភាពមាតា និងទារក ឆ្នាំ ២០១៦-២០២០
2- ការអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០២១-២២
3- គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា ឆ្នាំ២០១៦-២០៣០។ បញ្ជីគោលដៅដែលបានកែសម្រួល និងសូចនាករតាមគោលដៅ ខែកក្កដា ឆ្នាំ២០២២ ក្រសួងផែនការ
4- យុទ្ធសាស្ត្រជាសកល ដើម្បីសុខភាពស្ត្រី កុមារ និងមនុស្សវ័យជំទង់ ឆ្នាំ២០១៦-២០៣០។ WHO
5- យុទ្ធសាស្ត្រឆ្ពោះទៅបញ្ឈប់អត្រាមរណភាពមាតាដែលអាចទប់ស្កាត់បាន (EPMM) ឆ្នាំ២០១៥។ WHO
6- ការបណ្តុះបណ្តាល និងគន្លង នៃវិជ្ជាជីវៈឆ្មបនៅប្រទេសកម្ពុជា ឆ្នាំ២០១៧។ គណៈឆ្មបកម្ពុជា
7- ផែនការយុទ្ធសាស្ត្ររបស់គណៈឆ្មបកម្ពុជា ឆ្នាំ២០២១-២០២៥។ គណៈឆ្មបកម្ពុជា
8- ផែនការអភិវឌ្ឍន៍ធនធានមនុស្ស នៃវិស័យសុខាភិបាល ឆ្នាំ២០២៤-២០៣៣, ក្រសួងសុខាភិបាល
9- តម្រូវការធនធានមនុស្ស នៃវិស័យសុខាភិបាលសម្រាប់ការគ្របដណ្តប់សុភាពជាសកល និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ២០១៦។ WHO
10-ការពិនិត្យឡើងវិញផែនការកែលម្អ EmONC ឆ្នាំ២០២០។ ក្រសួងសុខាភិបាល
11-ផែនការកែលម្អ EmONC ឆ្នាំ២០២១-២០២៥ ខែមករា ឆ្នាំ២០២២។ ក្រសួងសុខាភិបាល
12-សេចក្តីថ្លែងការណ៍របស់ WHO ស្តីពីការសម្រាលកូនដោយវះកាត់ ឆ្នាំ២០១៥។ WHO
13-ផែនការសកម្មភាពរយៈពេលប្រាំឆ្នាំសម្រាប់ការថែទាំទារកទើបនឹងកើតនៅកម្ពុជា ខែធ្នូ ឆ្នាំ២០១៥។ MoH
14-ផែនការសកម្មភាព EENC ថ្នាក់តំបន់ គោលដៅត្រូវបានបន្តរហូតដល់ឆ្នាំ២០៣០។ ខែធ្នូ ឆ្នាំ២០២២។ WHO
15-របាយការណ៍វឌ្ឍនភាព EENC រៀងរាល់ពីរឆ្នាំម្តង លើកទីពីរ (ឆ្នាំ២០១៦-២០១៧)។ WHO តំបន់ប៉ាស៊ីហ្វិកខាងលិច
16-របាយការណ៍វឌ្ឍនភាព EENC រៀងរាល់ពីរឆ្នាំម្តង លើកទីបី (ឆ្នាំ២០១៨-២០២០)។ WHO តំបន់ប៉ាស៊ីហ្វិកខាងលិច
17-ការបញ្ឈប់មរណភាពទារកទើបនឹងកើត និងទារកកើតស្លាប់ ដែលអាចទប់ស្កាត់បាន ត្រឹមឆ្នាំ២០៣០។ ភាពរីកចម្រើនឆាប់ជាងមុន ឆ្ពោះទៅរកការគ្របដណ្តប់សុខភាពជាសកលប្រកបដោយគុណភាពកខ្ពស់ នៅឆ្នាំ ២០២០-២០២៥ ខែកក្កដា ឆ្នាំ២០២២។ WHO, Unicef.
18-គោលការណ៍ណែនាំអំពីសំណុំសកម្មភាពបង្គ្រប់ដើម្បីអភិវឌ្ឍន៍មន្ទីរពេទ្យបង្អែក ខែមិថុនា ឆ្នាំ២០១៤។ ក្រសួងសុខាភិបាល
19-គោលការណ៍ណែនាំអំពីសំណុំសកម្មភាពអប្បបរមា ឆ្នាំ២០១៨។ ក្រសួងសុខាភិបាល
20-របាយការណ៍សន្និបាទសុខាភិបាល ឆ្នាំ២០១៨-២០២២។ ក្រសួងសុខាភិបាល
21-របាយការណ៍ប្រព័ន្ធគ្រប់គ្រងព័ត៌មានសុខាភិបាល ឆ្នាំ២០២២
22-ផែនការអភិវឌ្ឍធនធានមនុស្សសុខាភិបាល ឆ្នាំ២០១៦-២០២០។ ក្រសួងសុខាភិបាល

23-គោលការណ៍ណែនាំសម្រាប់កញ្ចប់តាវកាលិក និងការទូទាត់ប្រាក់ដល់អ្នកផ្តល់សេវាសម្រាប់មូលនិធិសមធម៌សុខភាពសម្រាប់ជនក្រីក្រ ខែមិថុនា ឆ្នាំ២០១៨។ ក្រសួងសុខាភិបាល

24- ក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦-២០២៥ ខែមិនា ឆ្នាំ២០១៧។ **CoM RGC**

25- ក្របខណ្ឌអនុវត្តការជំរុញបង្កើនការងារថែទាំសុខភាពបឋម ឆ្នាំ២០២៣។ ក្រសួងសុខាភិបាល

26- គណនីយភាពសុខាភិបាល ឆ្នាំ២០១២-២០១៦។ របាយការណ៍ចំណាយ នៃវិស័យសុខាភិបាល ឆ្នាំ២០១៩។ **WHO**